**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ ឆ្ពោះទៅពេលអនាគត

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ឺយ ស្រីល័ក្ខ**
**ម៉ក់ ស្រីមុំ**

សាស្ត្រាចារ្យណែនាំ
លោក **សួន ចំរើន**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# អារម្ភកថា

របាយការណ៍បញ្ចប់ការសិក្សាដែលមានចំណងជើងថា "ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត" ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើការបង្ហាញនៅពេលនេះ គឺជាការចាប់ផ្តើមនូវប្រតិបត្តិការទិញលក់មូលបត្រ ការផាត់ទាត់ និងទូទាត់មូលបត្រកម្ពុជា ដែលដំណើរការយ៉ាងមមាញឹក នៅលើទីផ្សារមូលបត្រកម្ពុជាជារៀងរាល់ថ្ងៃ។

ដូចនេះក្នុងនាមយើងជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានរៀបចំខ្លឹមសារមួយនេះឡើងក្នុងគោលបំណងចូលរួមចំណែកធ្វើការផ្សព្វផ្សាយ និងធ្វើបទបង្ហាញនូវការវិវត្តនៃទីផ្សារមូលបត្រកម្ពុជា ដើម្បីជាចំណេះដឹងដល់សិស្សនិស្សិតជំនាន់ក្រោយ ក៏ដូចជាមហាជន។ ជាពិសេសបង្ហាញអំពី ដំណើរការជួញដូរមូលបត្រនៅលើទីផ្សារបន្ទាប់របស់វិនិយោគិន រួមទាំងយន្តការនៃការផាត់ទាត់និងទូទាត់ ការរក្សាទុកមូលបត្រ និងតួនាទី ផ្សេងៗរបស់ផ្សារមូលបត្រកម្ពុជា។

ក្រុមយើងខ្ញុំសង្ឃឹមថា របាយការណ៍បញ្ចប់ការសិក្សានេះនិងអាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវចំពោះនិស្សិតជំនាន់ក្រោយ ទុកជាឯកសារនិងជួយជាជំនួយស្មារតីចំពោះមិត្តអ្នកអានទាំងអស់ស្វែងយល់កាន់តែច្បាស់ពីប្រតិបត្តិការ និងតួនាទីរបស់ផ្សារមូលបត្រកម្ពុជាបានទូលំទូលាយជាងមុន។ បើទោះបីឯកសារនេះរៀបចំយ៉ាងយកចិត្តទុកដាក់ក៏ដោយ ក៏យើងខ្ញុំជឿជាក់ថានឹងមានកំហុសឆ្គងមួយចំនួនកើតមានឡើងជាពុំខាន អាស្រ័យហេតុដូចនេះយើងខ្ញុំសូមអធ្យាស្រ័យ និងទទួលយកដោយក្តីរីករាយនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអានគ្រប់រូប។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ម៉ឹយ ស្រីល័ក្ខ និង ម៉ក់ ស្រីមុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក ធនាគារ និង ហិរញ្ញវត្ថុ ឆ្នាំទី៤ ថ្នាក់ B4C6 និង B4A2 ជំនាន់ទី១០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ឆ្នាំសិក្សា ២០១៣-២០១៧ ដែលបានចុះកម្មសិក្សានៅគណៈកម្មការមូលបត្រ កម្ពុជា ប្រកបដោយជោគជ័យគឺ អាស្រ័យដោយមានការឧត្ថម្ភគាំទ្រ និងជ្រោមជ្រែងយ៉ាងកក់ក្តៅពីសំណាក់មជ្ឈដ្ឋានជុំវិញជាច្រើន ។ អាស្រ័យហេតុនេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក និងអ្នកម្តាយ ដែលជាអ្នកមានគុណទាំងពីរ និងបានផ្តល់កំណើតធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ផ្តល់នូវភាពស្រលាញ់ និងការផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងកំលាំងកាយ កំលាំងចិត្ត និងទាំងផ្នែកស្មារតីព្រមទាំងផ្នែកសំភារៈដោយគ្មានការត្អូញត្អែរដល់រូបកូនតាំងពីតូចរហូតដល់បញ្ចប់បរិញ្ញាបត្រ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដោយសេចក្តីគោរព និងប្រកបដោយការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុតដែលបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយ កំលាំងចិត្ត ប្រាជ្ញាស្មារតី ក្នុងការបង្ហាត់បង្រៀន ណែនាំ ផ្តល់នូវដំបូន្មានអប់រំ ចំណេះដឹងជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍដល់យើងខ្ញុំ អស់រយៈពេលបួនឆ្នាំកន្លងមកនេះ ។
- លោកសាស្ត្រាចារ្យ សួន ចំរើន ដែលបានណែនាំ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងចង្អុលបង្ហាញក៏ដូចជាផ្តល់នូវគំនិត និងយោបល់ល្អៗក្នុងការប្រើប្រាស់វិធី សាស្ត្រស្រាវជ្រាវ ប្រមូលព័ត៌មាន និងកែសម្រួលរៀបចំរបាយការណ៍កម្មសិក្សានេះ ជាពិសេសជួយកែលំអចំណុចខ្វះខាត ទាំងឡាយដើម្បីធ្វើអោយរបាយការណ៍នេះកាន់តែមានលក្ខណៈល្អប្រសើរឡើង ។
- ឯកឧត្តមអគ្គនាយកគណៈកម្មការមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយករង លោកប្រធាននាយកដ្ឋាន និងលោកប្រធានការិយាល័យរួមទាំងមន្ត្រីបម្រើការនៅគណៈកម្មការមូលបត្រកម្ពុជាទាំងអស់ដែលបានអនុញ្ញាតផ្តល់លទ្ធភាព និងឱកាសអោយយើងខ្ញុំចុះកម្មសិក្សានៅ គណៈកម្មការមូលបត្រកម្ពុជា។ ជាពិសេសចំពោះមន្ត្រីនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ដែលបានផ្តល់នូវ ឯកសារ ដំបូន្មាន គំនិត និងយោបល់ល្អៗ ក៏ដូចជាផ្តល់ភាពងាយស្រួលក្នុងការឆ្លើយតបនូវរាល់ចម្ងល់ផ្សេងៗ និងការយកចិត្តដាក់មកលើយើងខ្ញុំ

អំឡុងពេលចុះកម្មសិក្សានេះ ដែលធ្វើឲ្យយើងខ្ញុំទទួលបានចំណេះដឹងនិងបទពិសោធន៍ការងារនៅក្នុងវិស័យមូលបត្រ។

- រៀមច្បងដែលបានបន្សល់ទុកនូវស្នាដៃ ដែលជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្ថែម និងជាប្រភពឯកសារយោងដ៏មានប្រយោជន៍ដល់យើងខ្ញុំ។
- មិត្តរួមជំនាន់ទាំងអស់គ្នាដែលតែងតែបានផ្តល់នូវកំលាំងចិត្ត កំលាំងកាយ ក្នុងការជួយជ្រោមជ្រែងរៀបចំរបាយការណ៍ និងអំឡុងពេលសិក្សាជាមួយគ្នាអស់ពេលបួនឆ្នាំកន្លងមក។ពិសេសរាល់ពេល យើងខ្ញុំត្រូវការជំនួយពួកគាត់តែងតែឆ្លៀតពេលវេលាដ៏មានតម្លៃរបស់ពួកគាត់ក្នុងការជួយយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សេរីមង្គល វិបុលសុខ ជូនចំពោះ អ្នកមានគុណទាំងអស់អោយជួបប្រទះនូវពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាឃ្លាតឡើយ។

# សេចក្ដីផ្ដើម

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ស្ថានភាពទូទៅនៃ
# គណៈកម្មការមូលបត្រ

# ជំពូកទី៣
# ដំណើរការប្រតិបត្តិការ
# ទីផ្សារមូលបត្រឆ្ពោះទៅ
# ពេលអនាគត

# ឯកសារយោង

# ឧបសម្ព័ន្ធ

# សន្និដ្ឋាន
# និងអនុសាសន៍

# មាតិកា


អក្សរកាត់ ........ iv
បញ្ជីតារាង ........ v
បញ្ជីរូប ........ vi
បញ្ជីឧបសម្ព័ន្ធ ........ vii


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២
៦.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី១
## ការរំលឹកទ្រឹស្តី


១.១.ទីផ្សារហិញ្ញវត្ថុ ........ ៥
១.១.១.ទីផ្សាររូបិយវត្ថុ ........ ៥
១.១.២. ទីផ្សារមូលធន ........ ៥
១.២.១.និយមន័យ ........ ៦
១.២.២.ប្រវត្តិទីផ្សារមូលបត្រកម្ពុជា ........ ៦
១.២.៣.១.មូលបត្រមហាជន ........ ៧
១.២.៣.២.មូលបត្ររដ្ឋ ........ ១០
១.២.៤.យន្តការទីផ្សារ ........ ១០
១.២.៤.១.ទីផ្សារដំបូង (Primary Market) ........ ១០
១.២.៤.១.ទីផ្សារបន្ទាប់ (Secondary Market) ........ ១១
១.២.៥.១.ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure ........ ១២
១.២.៥.២. អន្តរការីទីផ្សារ (Intermediary) ........ ១២
១.២.៥.៣ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Issuer) ........ ១៣

១.៤.គុណសម្បត្តិ និង គុណវិបត្តិនៃទីផ្សារមូលបត្រនៅក្នុងសេដ្ឋកិច្ចកម្ពុជា ........................... ១៣

## ជំពូកទី២

## ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រ

២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រ........................................................... ១៦
២.២.១.ចក្ខុវិស័យ........................................................................................................ ១៧
២.២.២.បេសកម្ម.......................................................................................................... ១៧
២.៣. និមិត្តសញ្ញា និងទីកន្លែងរបស់គណៈកម្មការបូលបត្រ................................................... ១៧
២.៣.១.រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា ........................................................................ ១៧
២.៣.២.ត្រារបស់គណៈកម្មការមូលបត្រ ............................................................................ ១៨
២.៣.៣.ទីកន្លែងរបស់គណៈកម្មការមូលបត្រ...................................................................... ១៩
២.៤.សមាសភាពរបសគណៈកម្មការមូលបត្រកម្ពុជា ........................................................... ១៩
២.៥.មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា ................................................................. ២០
២.៦.រចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា ................................................ ២០

## ជំពូកទី៣

## ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត

៣.១.តួអង្គសំខាន់ៗដែលចូលរួមក្នុងការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់ ........................ ២១
៣.១.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)................................................................ ២១
៣.១.២. ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ............................................................................ ២១
៣.១.៣.ក្រុមហ៊ុនមូលបត្រ.............................................................................................. ២២
៣.១.៤.វិនិយោគិន (Investor) ....................................................................................... ២៥
៣.១.៦.ភ្នាក់ងារទូទាត់មូលបត្រទាក់ទងនិងសាច់ប្រាក់ ...................................................... ២៥
៣.២.ដំណើរការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................ ២៦
៣.២.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ.......................................................................... ២៦
៣.២.២. ការបើកគណនីជួញដូរ ....................................................................................... ២៧
៣.២.៣.ការដាក់បញ្ជា ................................................................................................... ២៨
៣.២.៤. ប្រតិបត្តិការជួញដូរមូលបត្រ................................................................................. ២៨
៣.២.៥. ដំណើរការនៃការទិញ-លក់មូលបត្រ....................................................................... ៣៥

៣.២.៦. ប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់ .......... ៣៨
៣.២.៧.ប្រតិបត្តិការរក្សាទុកមូលបត្រ .......... ៤១
៣.៣.ការវិវត្តនៃកិច្ចដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ .......... ៤២
៣.២.១ ប្រព័ន្ធជួញដូរតាមទូរស័ព្ទដៃ .......... ៤២
៣.២.២.កិច្ចដំណើរការសមាហរណកម្មទីផ្សារមូលបត្រក្នុងតំបន់អាស៊ាន .......... ៤៣
៣.២.៣.ការវិភាគលើភាពខ្លាំង ភាពខ្សោយ .......... ៤៤

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន .......... ៤៥
២.អនុសាសន៍ .......... ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

**-គ.ម.ក** = គណៈកម្មការមូលបត្រកម្ពុជា

**-ផ.ម.ក** = ផ្សារមូលបត្រកម្ពុជា

-CCP = Central Counter Party

-CSA = Cash Securities Exchange

-IPO = Initial Public Offering

-SECC = Securities and Exchange Commission Cambodia

-SF = Securities Firm

-CSO = Clearing and Settlement Operator

-DVP = Delivery versus Payment

-OTC = Over the Centre

## បញ្ជីតារាង


តារាងទី១៖ ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ..........................................................៣០

តារាងទី២៖ ដែនកំណត់នៃបម្រែបម្រួលថ្លៃ................................................................៣២

តារាងទី៣៖ គោលការណ៍ដេញថ្លៃ.........................................................................៣៣

តារាងទី៤៖ ដេញថ្លៃដោយយកថ្លៃតែមួយ.................................................................៣៤

តារាងទី៥៖ ដេញថ្លៃដោយយកថ្លៃច្រើន...................................................................៣៥

# បញ្ជីរូប

រូបភាពទី១៖ រូបសញ្ញា និងអត្ថន័យនៃគ.ម.ក. ..........................................................១៧
រូបភាពទី២៖ ត្រារបស់គ.ម.ក..............................................................................................១៨
រូបភាពទី៣៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ម.ក..........................................................២០
រូបភាពទី៤៖ ម៉ោងជួញដូរ នឹងថ្ងៃជួញដូរ.......................................................................២៩
រូបភាពទី៥៖ គំនូសតាងដំណើរការជួញដូរមូលបត្រ.....................................................៣៧
រូបភាពទី៦៖ អន្តរាគមន៍នៃ ផ.ក.ម......................................................................................៣៨
រូបភាពទី៧៖ គំនូសបំព្រួញអំពីពេលវេលានៃការផាត់ទាត់ និងទូទាត់..............................៤០
រូបភាពទី៨៖ គំនូសតាងដំណើរការផាត់ទាត់ និងទូទាត់មូលបត្រ....................................៤១

# បញ្ជីឧបសម្ព័ន្ធ

បញ្ជីឧបសម្ព័ន្ធទី១៖ វិធានប្រតិបត្តិការទីផ្សារមូលបត្រ
បញ្ជីឧបសម្ព័ន្ធទី២៖ វិធានផាត់ទាត់ និងទូទាត់មូលបត្រ
បញ្ជីឧបសម្ព័ន្ធទី៣៖ វិធានរក្សាទុកមូលបត្រ
បញ្ជីឧបសម្ព័ន្ធទី៤៖ វិធាននៃការស្នើសុំអគ្គសញ្ញាណវិនិយោគ

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

យើងសង្កេតឃើញថានាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានសន្តិភាព និង មានការរីកចម្រើនស្ទើរគ្រប់វិស័យដូចជា កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។ វិស័យទាំងអស់នេះអាចមានការអភិវឌ្ឍទៅបានដោយមាន ការដឹកនាំតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល បានអនុញ្ញាតឲ្យមានការគាំទ្រពីវិស័យហិរញ្ញវត្ថុដូចជា ធនាគារ មីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រង និង ជាពិសេសវត្តមានចុងក្រោយរបស់វិស័យមូលបត្រ។ វិស័យហិរញ្ញវត្ថុជាវិស័យមួយដ៏សំខាន់ក្នុងការ កៀងគរមូលធនក្នុងការផ្គត់ផ្គង់ អាជីវកម្មប្រជាពលរដ្ឋ វិនិយោគិនក្នុងស្រុក និងក្រៅស្រុក។

ចំពោះវិស័យមូលបត្រ គឺជាវិស័យមួយដែលកំពុងទទួលបានការពេញនិយម និងការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់វិនិយោគិន នៅបណ្ដាប្រទេសមួយចំនួនជាពិសេស គឺប្រទេសដែលមានការអភិវឌ្ឍខ្ពស់។ ការវិនិយោគលើមូលបត្រ គឺជាវិធីសាស្ត្រហិរញ្ញវត្ថុមានប្រសិទ្ធិភាពមួយក្នុងការជួយបង្កើនដើមទុនដើម្បីពង្រីកអាជីវកម្ម ដែលជាកត្តាមួយធ្វើឲ្យសេដ្ឋកិច្ចក្នុងប្រទេសមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ បច្ចុប្បន្នវិស័យមួយនេះបាននឹងកំពុងព្យាយាមពង្រីកវិសាលភាពរបស់ខ្លួននៅក្នុងព្រះរាជណាចក្រកម្ពុជា។ យ៉ាងណាមិញ ការជួញដូរមូលបត្រក្នុងប្រទេសកម្ពុជានៅមិនទាន់មានសន្ទុះខ្លាំងនៅឡើយទេ បើទោះជាវិស័យនេះមានវត្តមាននៅកម្ពុជាអស់រយៈពេលប្រមាណជាង ៥ឆ្នាំរួចមកហើយ។ បើយោងតាមរាជរដ្ឋាភិបាល ជាពិសេសអ្នកជំនាញផ្នែកមូលបត្រ វាត្រូវការរយៈពេលច្រើនឆ្នាំសម្រាប់ទីផ្សារមួយនេះក្នុងការអភិវឌ្ឍខ្លួនដើម្បីទទួលបានការចាប់អារម្មណ៍ពីអ្នកវិនិយោគ និងក្រុមហ៊ុននានានៅកម្ពុជា ព្រោះវិនិយោគិនត្រូវការស្វែងយល់បន្ថែមពីដំណើរការនៃវិស័យមួយនេះឲ្យបានច្បាស់ជាមុនសិន។

ហេតុដូចនេះហើយបានជាយើងខ្ញុំជ្រើសរើសយកប្រធានបទដែលស្ដីពី "ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត" ក្នុងគោលបំណងដើម្បីជួយផ្ដល់ចំណេះដឹង និងជាព័ត៌មានបន្ថែមសម្រាប់សាធារណជន ជាពិសេសយើងខ្ញុំចង់បង្ហាញនូវវត្តមានថ្មីៗនៃប្រតិបត្តិការមូលបត្រដែលនឹងចាប់ផ្ដើមមាននាពេលឆាប់ៗនេះ។ វាជាព័ត៌មានថ្មីមួយសម្រាប់ចែកជូនដល់សាធារណជន និងនិស្សិត។

## ២.ចំណោទបញ្ហា

រយៈពេល ៥ (ប្រាំ) នៃការកកើតមូលបត្រ ជារយៈពេលមួយខ្លី ដែលធ្វើឲ្យវិនិយោគិន ក៏ដូចជាប្រជាពលរដ្ឋ មិនទាន់មានការយល់ដឹងច្បាស់អំពីវិស័យមូលបត្រ។ ជាមូលហេតុ ដែលធ្វើឲ្យក្រុមការងារមូលបត្រត្រូវរកវិធីសាស្ត្រ ងាយស្រួល និង មានភាពទាក់ទាញក្នុងការវិនិយោគមួយនេះ។ ដោយផ្អែកលើចំណោទបញ្ហាខាងលើ ដូចនេះ តើដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត មានការវិវត្តយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណងដូចខាងក្រោម៖

- ការវិវត្តនៃប្រតិបត្តិការទីផ្សារមូលបត្រ
- យល់ដឹងអំពីតួនាទីរបស់តួអង្គពាក់ព័ន្ធដែលចូលរួមក្នុងដំណើរការនៃការជួញដូរមូលបត្រ
- វិធីសាស្ត្រដើម្បីក្លាយទៅជាវិនិយោគិន
- របៀបនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ
- ស្វែងយល់ពីសារៈសំខាន់នៃការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពកិច្ចការសិក្សាស្រាវជ្រាវមួយនេះ គឺផ្តោតទៅលើដំណើរការជួញដូរនៅលើទីផ្សារបន្ទាប់ តែប៉ុណ្ណោះ និងកំណត់ពីឆ្នាំ ២០១២ រហូតដល់ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០១៧។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សានេះអាចសម្រេចទៅបានភាពជោគជ័យដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណក្នុងការស្រាវជ្រាវ ហើយក្នុងស្រាវជ្រាវនេះយើងប្រមូលបានទិន្នន័យពីរយ៉ាងគឺ៖

- ទិន្នន័យចម្បង៖
  - ការធ្វើបទសម្ភាសនៅគណៈកម្មការមូលបត្រកម្ពុជា SECC (Securities and Exchange Commission of Cambodia)
  - ការសាកសួរដោយផ្ទាល់ទាក់ទងអំពីការជួញដូរមូលបត្រ ជាមួយនឹងបុគ្គលិកដែលធ្វើការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា SBI Royal Securities Plc និង Acleda Securities Plc
  - ធ្វើបទសម្ភាសជាមួយក្រុមការងារនៅផ្សារមូលបត្រកម្ពុជា CSX (Cambodia Securities Exchange)

- ការពន្យល់ណែនាំ និងការផ្តល់យោបល់បន្ថែមពីសំណាក់លោកសាស្ត្រាចារ្យណែនាំ

- ទិន្នន័យបន្ទាប់បន្សំ
  - ឯកសារពីបណ្ណាល័យសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ឯកសារសារណាឬរបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតរៀមច្បងមុនៗ
  - ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទតាមរយៈប្រព័ន្ធអ៊ីនធឺណេត
  - ឯកសារដែលផ្តល់ដោយមន្ត្រីគណៈកម្មការមូលបត្រដូចជា ច្បាប់ អនុក្រឹត្យ និង ឯកសារពាក់ព័ន្ធផ្សេងៗ។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- **ចំពោះយើងខ្ញុំ** ដែលជាអ្នកស្រាវជ្រាវទៅលើប្រធានបទនេះ ទទួលបានការបង្កើននូវចំណេះដឹងដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដែលកាលពីមុនមិនមានការយល់ច្បាស់។ យើងខ្ញុំទទួលបាននូវបទពិសោធន៍ ក្នុងការបំពេញការងារនៅគណៈកម្មការមូលបត្រ ជាពិសេស ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់រៀមច្បងនៅទីនោះ។ ពួកគាត់បានតម្រែតម្រង់ផ្លូវឲ្យក្រុមយើងខ្ញុំ យល់ដឹងអំពីប្រតិបត្តិការមូលបត្រ និងសកម្មភាពនានាក្នុងការងារមូលបត្រ។
- **ចំពោះគណៈកម្មការមូលបត្រ** យើងខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវនេះ អាចជាឯកសារដ៏ស្លួចស្តើងមួយសម្រាប់ គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** ក្នុងការពង្រឹងនិងការត្រួតពិនិត្យទីផ្សារ រួមទាំងបណ្តាក្រុមហ៊ុនមូលបត្រផ្សេងៗអោយមានប្រសិទ្ធភាពប្រសើរឡើង។
- **ចំពោះនិស្សិត និងអ្នកសិក្សាស្រាវជ្រាវ** អាចនឹងទទួលបាននូវការរំលឹកទ្រឹស្តីឡើងវិញដែលបានសិក្សាកន្លងមក និងជាប្រភពឯកសារសម្រាប់និស្សិតជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់បន្ថែមទៀត។
- **ចំពោះមជ្ឍដ្ឋានខាងក្រៅ** វាជារបាយការណ៍ដែលផ្តល់ជាព័ត៌មាន និងឯកសារសម្រាប់មជ្ឍដ្ឋានអ្នកអានទូទៅដែលមានបំណងចង់ដឹងពីវិស័យនេះ ជាពិសេសសម្រាប់ក្រុមហ៊ុនមូលបត្រ និងអ្នកវិនិយោគសាធារណៈដែលមានចំនូលចិត្តចូលរួមខាងវិស័យនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះ ប្រកបទៅដោយរលូននិងចំគោលដៅដែលបានគ្រោងទុក ក្រុមយើងខ្ញុំក៏បានបបង្កើតចេញជាប្លង់គំរូដូចខាងក្រោម៖

-សេចក្តីផ្តើម៖ ស្ថានភាពទូទៅនៃការស្រាវជ្រាវដែលបញ្ជាក់ពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

-ជំពូកទី១៖ ការរំលឹកទ្រឹស្តី

-ជំពូកទី២៖ ទិដ្ឋភាពផ្សារមូលបត្រកម្ពុជា

-ជំពូកទី៣៖ ដំណើរប្រតិបត្តិការផ្សារមូលបត្រឆ្ពោះពេលអនាគត

-សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖ ធ្វើការសន្និដ្ឋានជារួមសម្រាប់ការសិក្សាស្រាវជ្រាវ និងផ្តល់ជាអនុសាសន៍មួយចំនួន។

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

## ១.១.ទីផ្សារហិរញ្ញវត្ថុ[1]

ទីផ្សារហិរញ្ញវត្ថុ មានតួនាទីសំខាន់ក្នុងការបម្លែងការសន្សំទៅឲ្យបុគ្គល ឬស្ថាប័នដែលត្រូវការធនធានទាំងនេះ។ ទីផ្សារហិរញ្ញវត្ថុ គឺជាបេះដូងនៃប្រព័ន្ធហិរញ្ញវត្ថុ ព្រោះវាកំណត់នូវបរិមាណឥណទានដែលអាចទទួលបាន ទាក់ទាញការសន្សំហើយកំណត់នូវអត្រាការប្រាក់ និងតម្លៃរបស់មូលបត្រ។

### ១.១.១.ទីផ្សាររូបិយវត្ថុ

ទីផ្សាររូបិយវត្ថុ (Money Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្ររយៈពេលខ្លីតិចជាងមួយឆ្នាំ ដែលមានដូចជា៖

- បណ្ណ័រតនាគារ (Treasury Bill/T-bill) ជាបណ្ណ័បំណុលរយៈពេលខ្លីតិចជាងមួយឆ្នាំរបស់រដ្ឋាភិបាលដែលបោះផ្សាយដោយរតនាគារក្នុងគោលបំណងប្រមូលថវិការរដ្ឋដើម្បីអភិវឌ្ឍន៍។ បណ្ណ័នេះត្រូវបានលក់ដោយធនាគារកណ្ដាល។
- ផលបត្រពាណិជ្ជកម្ម (Commercial Paper) ជាបណ្ណ័បំណុលរយៈពេលខ្លី ដែលបោះផ្សាយដោយធនាគារធំៗ ឬ ក្រុមហ៊ុនសាជីវកម្មក្នុងគោលបំណងសុំខ្ចីលុយពីទីផ្សារ ដើម្បីទូទាត់បំណុល ទំនិញ និងសេវាផ្សេងៗ។
- Banker Acceptance ជាបណ្ណ័បំណុលរយៈពេលខ្លី ដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មមានការទទួលខុលត្រូវ ឬមានការធានារបស់ធនាគារដែលបោះផ្សាយក្នុងគោលបំណងទូទាត់ទំនិញ សេវា ឬបំណុលផ្សេងៗនៅក្នុងពាណិជ្ជកម្មអន្តរជាតិ[2]។

### ១.១.២. ទីផ្សារមូលធន

ទីផ្សារមូលធន (Capital Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្រកម្មសិទ្ធិ (Equity Securities) និងឧបករណ៍បំណុលរយៈពេលវែង ដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែងមានដូចជា៖ បណ្ណ័ភាគហ៊ុនធម្មតា(Common Stock) បណ្ណ័ភាគហ៊ុនអាទិភាព (Preferred Stock) សញ្ញាប័ណ្ណ (Bond) ជាដើម។

[1] សាស្ត្រាចារ្យ សួន ចំរើន,(២០១៥-២០១៦) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ

## ១.២.ទីផ្សារមូលបត្រ

### ១.២.១.និយមន័យ

[3]ទីផ្សារមូលបត្រគឺជាកន្លែង សម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន គឺ«សំដៅដល់ទីផ្សារ ឬ ទីកន្លែងជួញដូរ មូលបត្រ ឬ ប្រព័ន្ធដែលផ្តល់ មធ្យោបាយ នៃការធ្វើសំណើរលក់ ផ្ទេរ ឬធ្វើការ ទិញ-លក់មូលបត្រ» ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវ បានជួញដូរលើទីផ្សារនេះរួមមាន មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

### ១.២.២.ប្រវត្តិទីផ្សារមូលបត្រកម្ពុជា[4]

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួល

[3] http://www.secc.gov.kh/khmer/faq.php?pn=2(ថតចម្លងនៅថ្ងៃទី២៥ មេសា ២០១៧)

[4] http://csx.com.kh/kh/about/profile.jsp?MNCD=10301(ថតចម្លងនៅទី២៥ មេសា ២០១៧)

អាជ្ញាបណ្ណ ជាប្រតិបត្តិករទីផ្សារ មូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពី គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរ មូលបត្រមហាជន។

### ១.២.៣. ប្រភេទមូលបត្រ

#### ១.២.៣.១.មូលបត្រមហាជន

សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុទ្បោមតាមច្បាប់[5]។ ជាទូទៅគេបែកចែងមូលបត្រជាបួនប្រភេទគឺៈ

##### ១.២.៣.១.១. មូលបត្រកម្មសិទ្ធិ ( Equity Securities )

សំដៅលើភាពជាម្ចាស់កម្មសិទ្ធិទៅលើក្រុមហ៊ុន ឬទ្រព្យសកម្មរបស់ក្រុមហ៊ុនមួយ ដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុនជាសាធារណៈ។ មូលបត្រកម្មសិទ្ធិមានពីរគឺៈ

**ក.ភាគហ៊ុនធម្មតា (Common Stock )**

ភាគហ៊ុនធម្មតា គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈ ភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ ម៉្យាងទៀតភាគហ៊ុនធម្មតាមានសិទ្ធិបោះឆ្នោតរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ប៉ុន្តែនៅពេលដែលក្រុមហ៊ុនក្ស័យធនការទូទាត់សងគឺនៅក្រោយភាគហ៊ុនបុរិមា។

**ខ. ភាគហ៊ុនបុរិមា (Preferred Stock )**

ភាគហ៊ុនបុរិមា ជាមូលបត្រកម្មសិទ្ធិពិសេសមួយ ដែលមានលក្ខណៈពីរ គឺលក្ខណៈជាឧបករណ៍កម្មសិទ្ធិផង និងឧបករណ៍បំណុលផង។ ជាទូទៅវាត្រូវបាន គេហៅថា ឧបករណ៍កូនកាត់។ មូលបត្រកម្មសិទ្ធិនេះមានឈ្មោះថាភាគហ៊ុនបុរិមា ព្រោះម្ចាស់ភាគហ៊ុននេះនឹងទទួលបានការទូទាត់ភាគលាភមុនម្ចាស់ ភាគហ៊ុនធម្មតា ប៉ុន្តែជាទូទៅម្ចាស់ភាគហ៊ុននេះពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ។ នៅពេលក្រុមហ៊ុនក្ស័យធនហើយលក់ទ្រព្យសកម្មរបស់ខ្លួន នោះម្ចាស់ភាគហ៊ុនបុរិមាទទួលបានចំណែកទូទាត់សងការខូចខាតមុនម្ចាស់ភាគហ៊ុនធម្មតា[6]។

---

[5] ច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ២០០៧

[6] siborann.blogspot.com/2011/09/blog-post_8065.html,Sep 14, 2011(ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)

**១.២.៣.១.២ មូលបត្របំណុល (Debt Securities)**

សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សារ ក្នុងទម្រង់ជាមូលបត្រដោយក្រុមហ៊ុនសាជីវកម្ម រដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលណាមួយ សម្រាប់បញ្ជាក់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលណាមួយដែលបានអោយប្រាក់ខ្ចី ហើយក្នុងគោលបំណងទទួលបានមូលធនបន្ថែមពីវិនិយោគិនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនតាមរយៈការខ្ចី។ មូលបត្របំណុលរួមមាន៖

**ក. សញ្ញាប័ណ្ណ (Bonds)**

[7]ជាមូលបត្របំណុលដែលចេញដោយរដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម។ ជាទូទៅអ្នកបោះផ្សាយលក់សញ្ញាប័ណ្ណត្រូវទូទាត់សងការប្រាក់ និងការប្រាក់ដើមនៅកាលបរិច្ឆេទជាក់លាក់។

**ខ. ឌីប៊ិនឈើ (Debentures)**

ជាប្រភេទមូលបត្រឧបករណ៍បំណុលមួយ ដែលបោះផ្សាយដើម្បីបង្កើនមូលធនបន្ថែមទៀត ហើយមូលបត្រប្រភេទនេះ មិនត្រូវបានធានាដោយទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយទេប៉ុន្តែវាត្រូវបានធានាកេរ្តិ៍ឈ្មោះរបស់អ្នកចេញផ្សាយ[8]។

**គ. ប័ណ្ណរតនាគាររយៈពេលខ្លី (Treasury Bills)**

ជាប្រភេទមូលបត្របំណុលរយៈពេលខ្លីដែលបោះផ្សាយដោយរដ្ឋាភិបាល ហើយវាមានរយៈពេលតិចជាងមួយឆ្នាំ។ ជាទូទៅអ្នកដែលវិនិយោគលើ T-bills គឺមិនទទួលបានការប្រាក់ទេ ប៉ុន្តែគេអាចទទួលបានប្រាក់ចំនេញពីការទិញក្នុងតំលៃអប្បហា(Discount) ។

**ឃ.វិញ្ញាបនបត្រប្រាក់បញ្ញើ (Certificate of deposits)**

ជាកិច្ចព្រមព្រៀមរវាងអ្នកវិនិយោគិន និងធនាគារដែលក្នុងនោះវិនិយោគិនយល់ព្រមដើម្បីរក្សាចំនួនទឹកប្រាក់នៃការដាក់ប្រាក់បញ្ញើនៅក្នុងធនាគារក្នុងការប្តូរសម្រាប់ធានានូវអត្រាការប្រាក់។ ជាទូទៅវាបោះផ្សាយដោយធនាគារពាណិជ្ជ ប៉ុន្តែគេអាចទិញវាតាមរយៈឈ្មួញកណ្តាល និង អ្នកចេញផ្សាយក្នុងតំលៃណាមួយដូចជាសញ្ញាបណ្ណដែរ។

**១.២.៣.១.៣. មូលបត្រដេរីវេទីវ ឬ ឧបករណ៍និស្សន្ទ (Derivative Securities)**

[9] ជាប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានតំលៃបានមកពីតំលៃមូលបត្រមូលដ្ឋានមួយ។ មូលបត្រដេរីវេទីវរួមមាន៖

---

[7] http://cambodia-financial-market.blogspot.com/2011/07/bond-sabay-securities-bond-share-sabay.html (ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)

[8] http://www.investopedia.com/terms/d/debenture.asp (ចូលទស្សនាថ្ងៃទី២៦ មេសា ២០១៧)

**ក. Option**

ជាសិទ្ធិតែមិនមែនជាកាតព្វកិច្ច ក្នុងការទិញឬលក់ទ្រព្យក្នុងតម្លៃកំណត់មួយជាក់លាក់។ Option ត្រូវបានចែកចេញជា **Call Option** និង **Put Option** ។ **Call Option** ផ្តល់សិទ្ធិក្នុងការទិញទ្រព្យសកម្ម ក្នុងថ្លៃកំណត់មួយព្រមព្រៀមលើកិច្ចសន្យា នៅកាលបរិច្ឆេទកំណត់ដែលហៅថា **Exercise price** ឬ **Strike price** ។ ចំណែកឯ **Put Option** ផ្តល់ជូនសិទ្ធិក្នុងការលក់ទ្រព្យសកម្ម លើថ្លៃកំណត់មួយនៅកាលបរិច្ឆេទកំណត់ជាក់លាក់មួយ។

**ខ. Forward**

ជាកិច្ចសន្យាដែលគេអាចទិញ-លក់បរិមាណឧបករណ៍ហិរញ្ញវត្ថុថ្ងៃនេះ តែប្រតិបត្តិការរបស់វានឹងធ្វើនៅពេលអនាគត។ នៅពេលដល់កាលវសាន្តអ្នកលក់ត្រូវប្រគល់ទំនិញទៅតាមកិច្ចសន្យា ហើយអ្នកទិញក៏ត្រូវទូទាត់តាមថ្លៃដែលចុះក្នុងកិច្ចព្រមព្រៀងនោះដែរ ទោះបីជានៅថ្ងៃកំណត់ថ្លៃរបស់វាប្រែប្រួលយ៉ាណាក៏ដោយ។ កិច្ចសន្យាបែបនេះត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារ អូ.ធី.ស៊ី(OTC)។

**គ. Future contract**

ជាកិច្ចសន្យាដែលមានលក្ខណៈដូចគ្នានឹង Forward តែកិច្ចសន្យានេះមានស្តង់ដារត្រឹមត្រូវប្រើសំរាប់ទិញ-លក់ទ្រព្យសកម្មអ្វីមួយនៅបេលអនាគត ហើយកិច្ចសន្យាបែបនេះត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារ Organized market។

**ឃ. Swaps**

ជាកិច្ចសន្យាជួញដូរមូលបត្រ ដោយយកមូលបត្រមួយប្តូរជាមួយមូលបត្រមួយផ្សេងទៀត។ កិច្ចសន្យាប្តូរមូលបត្រត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារ អូ.ធី.ស៊ី(OTC)។

**១.២.៣.១.៤ គម្រោងវិនិយោគរួម**

[10] គឺជាទម្រង់វិនិយោគមិន ផ្ទាល់មួយរបស់វិនិយោគិន។ គោលគំនិតសំខាន់នៃគ្រោងវិនិយោគរួមគឺ អនុញ្ញាតឲ្យមានការវិនិយោគដែលហានិភ័យត្រូវបានកាត់បន្ថយ ហើយអាចទទួលបាននូវផលកម្រៃខ្ពស់ជាង ការវិនិយោគដោយផ្ទាល់។ ហានិភ័យត្រូវបានកាត់បន្ថយ ដោយសារតែហានិភ័យនៃការវិនិយោគត្រូវបានបែងចែកក្នុងចំណោមវិនិយោគិនទាំងអស់។ប្រសិនបើវិនិយោគិន

[9] http://www.investopedia.com/exam-guide/series-65/alternative-investments/derivative-securities.asp (ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)

[10] សាស្ត្រាចារ្យ ញាន វណ្ណ:( ២០០៩) ហិរញ្ញប្បទានរបស់របស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយ:ទីផ្សារមូលបត្រ

ម្នាក់សម្រេចចិត្តធ្វើការវិនិយោគដោយផ្ទាល់តែឯកឯង គាត់ត្រូវទទួលរាប់រងនូវការខាតបង់ទាំងស្រុងតែម្នាក់ឯង។ ដោយឡែកការវិនិយោគតាមរយៈគម្រោងវិនិយោគរួម អនុញ្ញាតឲ្យគាត់ចែករំលែកហានិភ័យជាមួយវិនិយោគិនផ្សេងទៀតក្នុងគម្រោងវិនិយោគរួមតែមួយ។ ម៉្យាងទៀត ការវិនិយោគតាមរយៈគម្រោ វិនិយោគរួមអាចផ្តល់កម្រៃច្រើនជាងការវិនិយោគដោយផ្ទាល់ ដោយសារគម្រោងវិនិយោគត្រូវគ្រប់គ្រងដោយបុគ្គលជំនាញ ដែលជាបុគ្គលគ្រប់គ្រងមូលនិធិ។ អន្តរាគមន៍របស់អ្នកដែលមានវិជ្ជាជីវៈលើវិស័យនេះនឹងធានាផងដែរអំពីសុវត្ថិភាពក្នុងការវិនិយោគ។

**១.២.៣.២.មូលបត្ររដ្ឋ**

[11]សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ និង ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៅក្រោមច្បាប់នេះ រួមមានៈ

ក.ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ ។

ខ.សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។

គ.សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណាឬអត្រាប្តូរប្រាក់ឬអត្រាផ្សេងៗ។

ឃ.មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ។

ង.មូលបត្ររដ្ឋផ្សេងៗដទៃទៀត។

មូលបត្រទាំងអស់ខាងលើនេះ មិនរួមបញ្ចូលមូលបត្រដែលបោះផ្សាយដោយអាជ្ញាធរខេត្តក្រុង និង សហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះទេ។

### ១.២.៤.យន្តការទីផ្សារ

**១.២.៤.១.ទីផ្សារដំបូង** (Primary Market)

ទីផ្សារដំបូង ឬទីផ្សារបោះផ្សាយដំបូងសំដៅលើទីផ្សារដែលវិនិយោគទិញមូលបត្រផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ។

- លក្ខណៈរបស់ទីផ្សារដំបូង

\- ជាកន្លែងដែលមូលបត្រថ្មីត្រូវបានបង្កើតរាល់ពេលដែលក្រុមហ៊ុនធ្វើការបោះផ្សាយ ដែលត្រូវបានគេស្គាល់ថាជាសំណើនៃការបោះផ្សាយជាសាធារណៈលើកដំបូង(IPO)។

[11] ច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ២០០៧

- ប្រតិបត្តិការជួញដូរមូលបត្រនៅក្នុងទីផ្សារដំបូង ត្រូវបានធ្វើឡើងដោយផ្ទាល់រវាងក្រុមហ៊ុនដែលបោះផ្សាយមូលបត្រ ជាមួយនិងវិនិយោគិន។
- នៅក្នុងទីផ្សារដំបូង មូលបត្រអាចត្រូវបានដាក់លក់តែម្តងប៉ុណ្ណោះ។
- ថ្លៃមូលបត្រនៅក្នុងទីផ្សារដំបូងមានលក្ខណៈជាក់លាក់។
- ការលក់មូលបត្រត្រូវបានធ្វើឡើងដោយភ្នាក់ងារធានាទិញមូលបត្រ។

**១.២.៤.១.ទីផ្សារបន្ទាប់** (Secondary Market)

ទីផ្សារបន្ទាប់គឺជាទីផ្សារហិរញ្ញវត្ថុដែលចរាចរមូលបត្រដែលមានស្រាប់ និងធ្លាប់ធ្វើការជួញដូរបានម្តងរួចមកហើយនៅទីផ្សារដំបូង។ ទីផ្សារបន្ទាប់ជាទីកន្លែងដែលផ្តល់ឱកាសសម្រាប់វិនិយោគិនដោះដូរនូវភាគហ៊ុនពីវិនិយោគិនម្នាក់ទៅកាន់វិនិយោគិនម្នាក់ទៀតដែលស្ថិតនៅក្នុងតម្លៃកំណត់មួយដែលមានការព្រមព្រៀង និងពេញចិត្តដោយភាគីទាំងពីរ។

➢ លក្ខណៈរបស់ទីផ្សារ

- បង្កើតសន្ទនីយភាពនៃមូលបត្រ សំដៅដល់ភាពងាយស្រួលក្នុងការផ្លាស់ប្តូរពីមូលបត្រទៅជាសាច់ប្រាក់ភ្លាមៗតាមតម្លៃរបស់ទីផ្សារ។
- ប្រតិបត្តិការការជួញដូរមូលបត្រកើតឡើងក្រោយទីផ្សារដំបូង
- មានទីកន្លែងជាក់លាក់សម្រាប់ធ្វើការជួញដូរ
- ជំរុញឲ្យមានវិនិយោគិនថ្មីៗលើទីផ្សារ ដោយសារការឡើងចុះនៃថ្លៃមូលបត្រ ដែលនេះនឹងនាំមកនូវកំណើនវិនិយោគក្នុងប្រទេស ពិសេសការវិនិយោគក្នុងវិស័យឧស្សាហកម្ម។

**គំនូសបំព្រួញនៃការបែងចែករវាងទីផ្សារដំបូង និងទីផ្សារបន្ទាប់**




## ១.២.៥.តួអង្គសំខាន់ៗនៅក្នុងទីផ្សារមូលបត្រ

**១.២.៥.១.ហេដ្ឋារចនាសម្ព័ន្ធ** (Infrastructure)

ហេដ្ឋារចនាសម្ព័ន្ធ គឺជាតួអង្គមួយដ៏សំខាន់ក្នុងដំណើរការទ្រទ្រង់ទីផ្សារមូលបត្រ។

ហេដ្ឋារចនាសម្ព័ន្ធ គឺសំដៅដល់ទីតាំងប្រព័ន្ធជួញដូរមូលបត្រ ក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌគ្រប់គ្រងទីផ្សារមូលបត្រ និងធនធានមនុស្សសម្រាប់ចូលរួមក្នុងទីផ្សារមូលបត្រ។ ស្របគ្នានេះដែរ ហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ជាកត្តាមួយដ៏ចាំបាច់សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារមូលបត្រឲ្យមានដំណើរការល្អ ក្នុងគោលដៅបង្កើតទីផ្សារមូលបត្រមួយឲ្យប្រព្រឹត្តទៅដោយតម្លាភាព សន្ទនីយភាព ប្រសិទ្ធភាព សុវត្ថិភាព និងការពារវិនិយោគិន។

**១.២.៥.២. អន្តរការីទីផ្សារ** ( Intermediary )

អន្តរការីមូលបត្រ គឺជាអង្គភាព ឬបុគ្គលទាំងឡាយដែលប្រមូលផ្តុំវិនិយោគិន ហើយបង្ហាញ ឬណែនាំក្រុមហ៊ុនបោះផ្សាយទៅកាន់ទីផ្សារមូលបត្រ។ អន្តរការីទីផ្សារមូលបត្រមានចំនួនច្រើន ហើយដើរតួនាទីច្រើននៅក្នុងទីផ្សារ ដូចជា៖ អ្នកធានាទិញមូលបត្រ (Underwriter) ពាណិជ្ជករមូលបត្រ(Securities Dealers) ឈ្មួញជើងសារមូលបត្រ (Securities Brokers) ទីប្រឹក្សាវិនិយោគ (Investment Advisors)។

- អ្នកធានាទិញមូលបត្រ (Underwriter) គឺជាស្ថាប័នដែលផ្តល់សេវាកម្ម សម្រាប់ការបោះផ្សាយលក់មូលបត្រ និងមានសិទ្ធិក្នុងការជួញដូរមូលបត្រតាមបញ្ជាអតិថិជន និងខ្លួនឯងផ្ទាល់។
- ពាណិជ្ជករមូលបត្រ(Securities Dealers) សំដៅលើបុគ្គល ឬក្រុមហ៊ុនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួនផង និងសម្រាប់គណនីរបស់អតិថិជនផង។
- ឈ្មួញជើងសារមូលបត្រ (Securities Brokers) គឺជាអន្តរការីទីផ្សារមូលបត្រដែលដើរតួនាទីជាឈ្មួញកណ្តាលរវាងអ្នកលក់ និងអ្នកទិញក្នុងប្រតិបត្តិការទិញ-លក់មូលបត្រក្នុងនាម និងតាមការបញ្ជារបស់អតិថិជនខ្លួនដោយទទួលបានកម្រៃជើងសារ។
- ប្រឹក្សាវិនិយោគ (Investment Advisors) ជាក្រុមហ៊ុនដែលផ្តល់សេវាប្រឹក្សាផ្នែកវិនិយោគ ឬផ្តល់ជាការវិភាគលើមូលបត្រទៅឲ្យអតិថិជនដើម្បីទទួលបានកម្រៃ[12]។

**១.២.៥.៣ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ** ( Issuer )

[13] ក្រុមហ៊ុនបោះផ្សាយមូលបត្រ ជាតួអង្គមួយសំខាន់ដែលចូលរួមក្នុងដំណើរការទីផ្សារមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ គឺជាស្ថាប័នស្របច្បាប់ដែលបានចុះបញ្ជីលក់មូលបត្រ

---

[12] បៀន សាំង,មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ,២០០១១

[13] http://www.investopedia.com/terms/i/issuer.asp#axzz1zYB0cza,Investropedia,Issuer (ទស្សនានៅថ្ងៃទី៨ មិថុនា ២០១៧)

ក្នុងគោលបំណងទទួលបានហិរញ្ញប្បទានដើម្បីទ្រទ្រង់ ឬពង្រីកប្រតិបត្តិការរបស់ខ្លួន។ ក្រុមហ៊ុនបោះផ្សាយអាចជាសហគ្រាសសាធារណៈ ឬក្រុមហ៊ុនសាជីវកម្ម ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត( Public limited company) គឺជាក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុនិងឯកសារពាក់ព័ន្ធនានាដែលតម្រូវដោយច្បាប់។

**១.២.៥.៤. វិនិយោគិន** (Investor)

វិនិយោគិនគឺជាអ្នកដែលដាក់ទុនធ្វើវិនិយោគក្នុងវិស័យមូលបត្រក្នុងគោលបំណងទទួលបានប្រាក់ចំណេញ ឬ ភាគលាភនៅពេលដែលលក់មូលបត្រទៅវិញនាពេលអនាគត។ វិនិយោគិនអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ ជាទូទៅវិនិយោគិនមានពីរប្រភេទ៖

- វិនិយោគិនជារូបវន្តបុគ្គល ឬ ឯកត្តជន (Individual Investor) គឺសំដៅដល់អ្នកវិនិយោគដែលចាត់ចែង និងគ្រប់គ្រងមូលនិធិផ្ទាល់ខ្លួនរួមមានបុគ្គលធម្មតា ដែលវិនិយោគិនប្រភេទនេះជាវិនិយោគិនដែលជាទូទៅធ្វើការទិញ ឬ លក់មូលបត្រក្នុងទំហំមួយតូច ដែលគេអាចហៅថាជាអ្នកវិនិយោគរាយ។
- វិនិយោគិនជានីតិបុគ្គល (Institutional Investors) ជាប្រភេទនៃអ្នកវិនិយោគប្រកបដោយវិជ្ជាជីវៈដែលគ្រប់គ្រង និងចាត់ចែងមូលនិធិសម្រាប់ស្ថាប័នរួមមាន ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិរួម (Mutual Fund) និងមូលនិធិសោធននិវត្តន៍ (Pension Fund) ដែលវិនិយោគិនប្រភេទនេះធ្វើការវិនិយោគជាលក្ខណៈទ្រង់ទ្រាយធំ។

## ១.៤.គុណសម្បត្តិ និង គុណវិបត្តិនៃទីផ្សារមូលបត្រនៅក្នុងសេដ្ឋកិច្ចកម្ពុជា[14]

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងតែនិយាយថា ទីផ្សារមូលបត្រគឺជា និមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច សង្គម និងនយោបាយ) វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រទៅលើសេដ្ឋកិច្ចយ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រវាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះស្ទើរតែគ្រប់បណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុង

[14] http://www.secc.gov.kh/khmer/faq.php?pn=2 រៀបរៀងដោយ អ៊ឹង អ៊ូ ០៦ មករា ២០១២

អភិវឌ្ឍន៍ទាំងអស់ មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួរនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ ៖

១. ទីផ្សារមូលបត្រជួយជំរុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ចជាតិ។

២.ទីផ្សារមូលបត្រគឺជាមធ្យោបាយមួយប្រមែប្រមូល កៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។

៣.ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធី អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

៤.ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនបរទេស។

៥.ទីផ្សារមូលបត្រជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព។

៦.ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក ។

៧.ទីផ្សារមូលបត្រជួយបង្កើតនូវទំលាប់នៃការវិនិយោគ។

ទោះជាទីផ្សារមូលបត្រមានគុណសម្បត្តិ ដ៏សំខាន់សម្រាប់ជួយជំរុញកំណើនសសេដ្ឋកិច្ចជាតិក៏ដោយក៏មានគុណវិបត្តិមួយចំនួនដែរ ជាពិសេសសម្រាប់បណ្តាប្រទេសមានប្រព័ន្ធច្បាប់ទន់ខ្សោយ ដែលតែងតែជួបប្រទះនូវបញ្ហាដូចខាងក្រោមនេះ៖

១. ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់(Speculation) ៖ គឺជាការជួញដូរមួយ ដែលមានការគិតគូរយ៉ាងម៉ត់ចត់ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់នេះ អាចធ្វើឲ្យការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានាពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់របៀបនេះវានឹងបង្កឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះ ធ្វើឲ្យមានភាពងាយស្រួលនៅពេលពួកគេត្រូវរ៉ូវគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារមានពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬលើស ហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

២. ការជួញដូរផ្ទៃក្នុង ៖ មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរភាគហ៊ុនស្វែងរកចំណេញរបស់ខ្លួនដែលមាន

ឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ (ព័ត៌មានសម្ងាត់)។

៣.ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារៈ គឺជាសកម្មភាពណាមួយ ឬគេចវេសមិនធ្វើសកម្មភាពដែលបណ្តាលឲ្យ ឬអាចបណ្តាលឲ្យលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានភាពយល់ខុសចំពោះការជួញដូរមូលបត្រ ឬ ប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។

៤. សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឲ្យមានការយល់ខុសធ្ងន់ធ្ងរដែលបណ្តាលឲ្យសាធារណជនទិញ-លក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ឬថយចុះ ឬថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

៥. ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រតម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចសាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញ នូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

# ជំពូកទី២

# ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រ

## ២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រ[15]

ដើម្បីអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិដោយនិរន្តភាព រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទៅនូវ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០" ហើយក្រោយមកត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥"។ គោលបំណងនៃចក្ខុវិស័យនេះគឺ ដើម្បីពង្រឹង និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាក្នុងរយៈពេលវែង។ ទន្ទឹមនឹងនេះដើម្បីធានាបានថា វិស័យមូលបត្រកម្ពុជា អាចដំណើរការបានយ៉ាងរលូន ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកគតិយុត្តគឺជាកិច្ចការមួយដ៏សំខាន់។ ដូចនេះហើយចាប់ពីឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្តសំខាន់ៗមួយចំនួន រួមមានច្បាប់ស្តីពីមូលបត្ររដ្ឋ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៧ និងច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជនប្រកាសឲ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានចេញនូវ អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រ ចុះនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ រួមទាំងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពី ការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ចុះនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩។ ទន្ទឹមនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត គណៈកម្មការមូលបត្រកម្ពុជា ត្រូវបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីកាបោះផ្សាយនិងការជួញដូរមូលបត្រមហាជនបានអនុម័តរួច។

គណៈកម្មការមូលបត្រកម្ពុជា ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រ ប្រកបដោយសណ្តាប់ធ្នាប់ល្អ និងត្រឹមត្រូវក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មការមូលបត្រកម្ពុជាបានដាក់សម្ពោធឲ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ក្រោមអធិបតីភាពរបស់ឯកឧត្តមឧបនាយក រដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[15] និស្សិត ហ៊ាង បទម្យ និង ហង់ ពិសី ២០១៤, យន្តការនៃការផាត់ទាត់និងទូទាត់មូលបត្រកម្មសិទ្ធិ

## ២.២. ចក្ខុវិស័យ និង បេសកម្ម

ក្នុងគោលបំណងគ្រប់គ្រងវិស័យមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយស្ថេរភាព តម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់របៀបរៀបរយល្អ គណៈកម្មការមូលបត្រកម្ពុជា ដែលមានឈ្មោះជាភាសាអង់គ្លេសថា **“Securities and Exchange Commission of Cambodia”** មានចក្ខុវិស័យ និងបេសកម្មដូចខាងក្រោម៖

### ២.២.១.ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជា មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា។

### ២.២.២.បេសកម្ម

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និង ការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជួញលើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យតាមរយៈការទិញមូលបត្រនិងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។
- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៣. និមិត្តសញ្ញា និងទីតាំងរបស់គណៈកម្មការមូលបត្រ

### ២.៣.១.រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា

គណៈកម្មការមូលបត្រកម្ពុជា មានរូបសញ្ញា និងអត្ថន័យនៃរូបសញ្ញាដូចខាងក្រោម៖

រូបភាពទី១៖ រូបសញ្ញា និងអត្ថន័យនៃគ.ម.ក




- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ មូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា **"គណៈកម្មការមូលបត្រកម្ពុជា"** និងព័ទ្ធរង្វង់នៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា **"SECURITIES AND EXCHANGE COMMISSION OF CAMBODIA"**។

## ២.៣.២.ត្រារបស់គណៈកម្មការមូលបត្រ

រូបភាពទី២៖ ត្រារបស់គ.ម.ក.



ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬ ស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "**ព្រះរាជាណាចក្រកម្ពុជា**" ផ្នែកកណ្ដាលមានសញ្ញាប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា"**គណៈកម្មការមូលបត្រកម្ពុជា** "។

### ២.៣.៣.ទីកន្លែងរបស់គណៈកម្មការមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា បច្ចុប្បន្នមានទីតាំងបណ្ដោះអាសន្នស្ថិតនៅ ផ្ទះលេខ ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## ២.៤.សមាសភាពរបសគណៈកម្មការមូលបត្រកម្ពុជា

[16]ប្រធានគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សមាសភាពរបស់ គ.ម.ក. មានៈ

| | |
|---|---|
| ១-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១(មួយ)រូប |
| ២-តំណាងធនាគារជាតិនៃកម្ពុជា | ០១ (មួយ)រូប |
| ៣-តំណាងក្រសួងពាណិជ្ជកម្ម | ០១ (មួយ)រូប |
| ៤-តំណាងក្រសួងយុត្តិធម៌ | ០១ (មួយ)រូប |
| ៥-តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ០១ (មួយ)រូប |
| ៦-អគ្គនាយកនៃ គ.ម.ក | ០១ (មួយ)រូប |

៧-អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ០២(ពីរ)រូបដែលមានស្ថានភាពអព្យាក្រឹត ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវបានជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។ សមាសជិកនៃ **គ.ម.ក.** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬច្រើន ផ្នែកដូចជាពាណិជ្ជកម្មគ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងៗទៀតទៅតាមតម្រូវការជាក់ស្ដែង។

[16] ច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន,មាត្រា ៦

## ២.៥.មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម៖

១) គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រកម្ពុជានៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ។

២) ដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលពាក់ពន្ធ័និងទីផ្សារមូលបត្រ។

៣) កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

៤) កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។

៥) លើកកម្ពស់ និងជម្រុញដល់ការគោរពលក្ខខណ្ឌនៃច្បាប់នេះ។

៦)ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។

៧) ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨) បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

## ២.៦.រចនាសម្ព័ន្ធគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា

រូបភាពទី៣៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ម.ក.




(ប្រភព៖ http://www.secc.gov.kh)

# ជំពូកទី៣

# ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត

## ៣.១.តួអង្គសំខាន់ៗដែលចូលរួមក្នុងការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់នៅកម្ពុជា

### ៣.១.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)

[17] គណៈកម្មការមូលបត្រកម្ពុជា ជានិយ័តករវិស័យមូលបត្រ ឬស្ថាប័នរដ្ឋមួយដែលមានភារកិច្ចជាអ្នករៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធសម្រាប់ការបង្កើត និងត្រួតពិនិត្យទីផ្សារមូលបត្រ ព្រមទាំងជាអ្នកអនុញ្ញាត និងជាអ្នកផ្តល់អាជ្ញាប័ណ្ណគ្រប់បែបយ៉ាងទៅឲ្យភាគី ដែលពាក់ព័ន្ធនៅក្នុងដំណើរការប្រព្រឹត្តនៅក្នុងទីផ្សារ ។

### ៣.១.២. ផ្សារមូលបត្រកម្ពុជា (ផ.ម.ក)

នៅក្នុងទីផ្សារបន្ទាប់ ក៏ជាស្ថាប័នមួយដែលផ្តល់ការអនុញ្ញាត និងត្រួតពិនិត្យបណ្តាប្រតិបត្តិការទីផ្សារមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្នុងដំណើរការជួញដូរមូលបត្រក្នុងន័យការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកប ដោយ សណ្តាប់ធ្នាប់ និង ភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

#### ក. ប្រតិបត្តិករទីផ្សារមូលបត្រ

ប្រតិបត្តិករទីផ្សារមូលបត្រ ជាប្រតិបត្តិករជួរមុខ ក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ។

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជា៖

- ការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបន្សុីលើប្រតិបត្តិការបញ្ជាទិញ-លក់ មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្តឬ អេឡិចត្រូនិក។
- សកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក** ។

[17] គណៈកម្មការមូលបត្រ (www.secc.gov.kh)

**ខ.ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់**

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក ) ក៏ត្រូវបានអនុញ្ញាតអោយដើរតួជា ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ផងដែរដែលជាបុគ្គលដែលមានតួនាទីត្រួតពិនិត្យទាំងសងខាងរវាងប្រតិបត្តិការអ្នកលក់ និងអ្នកទិញ ដើម្បីជៀងវាងនូវហានិភ័យការផាត់ទាត់ ឬដំណើរការមិនល្អដែលកើតឡើងក្នុងការជួញដូរក្នុងវិស័យមូលបត្រ។ ប្រព័ន្ធផាត់ទាត់និងទូទាត់ផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឲ្យបានច្បាស់លាស់ និងធានាឲ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឲ្យអ្នកទិញ។

**គ.ប្រតិបត្តិកររក្សាទុកមូលបត្រ**

មុខងារចុងក្រោយរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) គឺប្រតិបត្តិកររក្សាទុកមូលបត្រដែលជាបុគ្គលមួយដែលយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនផ្តល់សេវាកម្មចំនួន ៣សំខាន់ៗ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ។ សេវាកម្មទាំងនោះមានដូចជាៈ

- កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
- ទទួលរក្សាទុកមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តីដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
- ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀតដែលទាក់ទងនឹងការផ្តល់សេវាកម្មដូចមានចែងក្នុងចំនុច (ក) និង (ខ)។

**៣.១.៣.ក្រុមហ៊ុនមូលបត្រ**

ក្រុមហ៊ុនមូលបត្រ( Securities Firm) សំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលទទួលបានអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយស្របទៅតាមច្បាប់។ នៅក្នុងទីផ្សារបន្ទាប់ក្រុមហ៊ុនមូលបត្រ អាចជាក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ និងអាជីវកម្មផ្សេងទៀតពាក់ព័ន្ធនឹងមូលបត្រ ដែលមានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)**។

**ក.ក្រុមហ៊ុនធានាទិញមូលបត្រ (Securities Underwriter)**

ក្រុមហ៊ុនធានាទិញមូលបត្រ គឺជាអង្គភាពមួយដែលធ្វើការគ្រប់គ្រងការចេញផ្សាយ និងការចែកចាយជាសាធារណនូវមូលបត្ររបស់ក្រុមហ៊ុនសាជីវកម្ម។ តួនាទីរបស់ភ្នាក់ងារធានាទិញមូលបត្រមានដូចជា៖

- ជួយឲ្យក្រុមហ៊ុនសាជីវកម្មមួយ អាចកើនឡើងនូវមូលធន និង ប្រាក់ចំនេញពីការធ្វើវិនិយោគិនដទៃតាមរយៈ ការផ្តល់ការប្រឹក្សាក្នុងការបោះផ្សាយលក់មូលបត្រជាលើកដំបូង (Initial Public Offering) ដែលក្នុងនោះមានការកំណត់ថ្លៃមូលបត្រ (Pricing) ទំហំទឹកប្រាក់ (Issue Amount) ចំនួនមូលបត្រដែលត្រូវបោះផ្សាយ និងការកំណត់ពេលវេលា នៃការបោះផ្សាយលក់មូលបត្រជាសាធារណ។
- ធានាទិញមូលបត្រទាំងអស់ ឬមូលបត្រមួយផ្នែក ពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រក្នុងគោលដៅលក់បន្តទៅដល់សាធារណជន។
- ទិញមូលបត្រដែលលក់មិនអស់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងគោលលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។

ក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** មានចំនួន ៦ក្រុមហ៊ុនគឺ៖

- ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc.)
- ក្រុមហ៊ុន អ អេច ប៊ី អូ អេស ខេ ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី លីមីធិត (RHB OSK Indochina Securities Limited)
- ក្រុមហ៊ុន កាណា ស៊ីឃ្យូរីធី អិលធីឌី (Cana Securities Ltd.)
- ក្រុមហ៊ុន កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (Campu Securities Plc.)
- ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI Royal Securities Plc.)
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

**ខ. ឈ្មួញជើងសារមូលបត្រ (Securities Broker)**

ឈ្មួញជើងសារ គឺជាបុគ្គលដែលធ្វើការជួញដូរមូលបត្រសម្រាប់អតិថិជន។ ពួកគេជាធម្មតាត្រូវបានតម្រូវឲ្យមានអាជ្ញាប័ណ្ណ ដើម្បីធ្វើសកម្មភាពនៅក្នុងនាមរបស់អ្នកទិញ និងអ្នកលក់មូលបត្រ។ ពួកគេអនុវត្តសេចក្តីណែនាំអំពីអ្នកបញ្ជាទិញ និងអ្នកលក់ ហើយទទួលបានកម្រៃជើងសារ ពីការទទួលទិញ និងលក់មូលបត្រ។ ដូចនេះ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** មានចំនួន ៣ គឺ៖

- ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACLEDA Securities Plc.)
- ក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី លីមីធិត (CAB Securities Plc.)
- ក្រុមហ៊ុន ខេមបូឌា-វៀតណាត ស៊ីឃ្យូរីធី ភីអិលស៊ី (Cambodia-Vietnam Securities Plc.) ។

**គ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealer)**

សំដៅលើបុគ្គល ឬក្រុមហ៊ុនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួនផង និង សម្រាប់គណនីរបស់អតិថិជនផង។ លក្ខណៈសម្បត្តិមួយចំនួនរបស់ពាណិជ្ជករមូលបត្ររួមមាន ៖

- ទិញ និងលក់មូលបត្រសម្រាប់គណនីរបស់ខ្លួន និងអតិថិជន
- ចូលរួមបង្កើតអោយមានទីផ្សារនៅក្នុងការទិញ និង លក់មូលបត្រ និង ផ្តល់នូវសេវាកម្មវិនិយោគដល់វិនិយោគិនទាំងឡាយ ។
- បំពេញការបញ្ជាទិញ ឬបញ្ជាលក់របស់អតិថិជន ដោយការទិញ ឬលក់មូលបត្រពីគណនីផ្ទាល់ខ្លួនរបស់គេ។

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** មានចំនួនមួយក្រុមហ៊ុនគឺក្រុមហ៊ុន ហ្គោដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី ( Golden Fortune (Cambodia) Securities Plc.)

**ឃ.ក្រុមហ៊ុនផ្តល់ប្រឹក្សាមូលបត្រ (Securities advisor)**

សំដៅលើបុគ្គល ឬអ្នកផ្តល់ដំបូន្មានអំពីការវិនិយោគលើមូលបត្រ។ លក្ខណៈសម្បត្តិរបស់អ្នកប្រឹក្សាមូលលបត្រគឺ៖

- ផ្តល់ដំបូន្មាន ឬការវិភាគអំពីមូលបត្រដោយផ្តលអនុសាសន៍ដោយផ្ទាល់ ឬប្រយោលដល់អតិថិជន ឬកាផ្តល់ការស្រាវជ្រាវ ឬគំនិតលើវិស័យមូលបត្រ ឬទីផ្សារមូលបត្រ។
- ចូលរួមនៅក្នុងបទប្បញ្ញាត្តិអាជីវកម្មដែលផ្តល់ដំបូន្មានអំពីមូលបត្រ។

ក្រុមហ៊ុនផ្តល់ប្រឹក្សាមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** មានចំនួន ២ គឺ៖

- ក្រុមហ៊ុន អង្គរ ឃែភីថល អ៊ែតវ៉ាយហ្ស៊ឺរ (Angkor Capital Advisors Co., Ltd.)
- ក្រុមហ៊ុន អេហ្វ.យូ.ជី.អាយ ហ្គោល (F.U.G.I GOLD Co., Ltd.)

**៣.១.៤.វិនិយោគិន** ( Investor )

អ្នកវិនិយោគិនសំដៅលើសាធារណជនទាំងរូបវន្តបុគ្គល និង នីតិដែលធ្វើការទិញលក់មូលបត្រ។

**៣.១.៥.ក្រុមហ៊ុនចុះបញ្ជី** ( Issuer )

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។

យោងតាមន័យសេដ្ឋកិច្ចក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាអ្នកផ្គត់ផ្គង់មូលបត្រនៅក្នុងទីផ្សារ។ ប្រសិនបើគ្មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទេ ក៏មិនមានមូលបត្រសម្រាប់ដាក់លក់នៅលើទីផ្សារមូលបត្រនោះដែរ ដូច្នេះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាតួអង្គសំខាន់មិនអាចខ្វះបាន នៅក្នុងទីផ្សារមូលបត្រ។ ការបោះផ្សាយលក់មូលបត្រ ដោយក្រុមហ៊ុនមូលបត្រ ត្រូវបានធ្វើឡើងដើម្បីគៀងគរមូលធន ឬដើមទុនពីសាធារណជន ឬ ពីវិនិយោគិនមូលបត្រ សម្រាប់ពង្រីកការ វិនិយោគ ឬបង្កើតការវិនិយោគថ្មីៗរបស់ក្រុមហ៊ុន។

**៣.១.៦.ភ្នាក់ងារទូទាត់មូលបត្រពាក់ព័ន្ធនិងសាច់ប្រាក់**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធមូលបត្រមានមុខងារ និងតួនាទី ដូចជា៖

- ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ខ្លួន និងធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ នៅក្នុងទីផ្សារមូលបត្រប្រកបដោយភាពត្រឹមត្រូវ និងតាមការកំណត់។
- ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធិភាព
- បំពេញប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធ និង មូលបត្រដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ។
- ត្រួតពិនិត្យនិងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានិភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។
- គោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមលក្ខខណ្ឌតម្រូវស្តីអំពីធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និង បច្ចេកវិទ្យា សម្រាប់ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រឲ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាព។
- គោរពតាមវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ និងវិធានពាក់ព័ន្ធផ្សេងទៀត។
- ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់សេវាផ្ទាល់ខ្លួន ដើម្បីធានាឲ្យមាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ។

- បំពេញកាតព្វកិច្ចផ្តល់របាយការណ៍ ព័ត៌មាននានា និងកាតព្វកិច្ចដទៃទៀតឲ្យបានត្រឹមត្រូវ ដូចមានចែងក្នុង ច្បាប់ អនុក្រឹត ប្រកាស និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមានចំនួន ៣គឺ
    - ធនាគារ អេស៊ីលីដា ភីអិលស៊ី
    - ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
    - ធនាគារ កាណាឌីយ៉ា អ.ក

## ៣.២.ដំណើរការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ៣.២.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

ជាជំហ៊ានបឋមវិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) និងជាសមាជិករបស់ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការជួញដូរមូលបត្រ។ បន្ទាប់ពីវិនិយោគិនជ្រើសរើសក្រុមហ៊ុនមូលបត្ររួចហើយ វិនិយោគិនត្រូវបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនត្រឹមត្រូវតាមការណែនាំរបស់ក្រុមហ៊ុនមូលបត្រ ហើយជាទូទៅត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម[18]៖

➢ **សម្រាប់វិនិយោគិនជារូបវន្តបុគ្គល**

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ដោយមានបិទរូបថត ដែលថតចំពីមុន ទំហំ ៤x៦ ពីរសន្លឹក។
- អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ មានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ញាតិខ្មែរ។
- លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ញាតិខ្មែរ។
- លិខិតបញ្ជាក់គណនីនៅធនាគារ

➢ **សម្រាប់វិនិយោគិនជានីតិបុគ្គល**

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ដោយមានបិទរូបថត ដែលថតចំពីមុន ទំហំ ៤x៦ ពីរសន្លឹក។

---

[18] គោលការណ៍ណែនាំ លេខ ០០១ គ.ម/គ.ណ.ន. ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាប័ណ្ណធ្វើអាជីវកម្មចតចម្លងមានបញ្ជាក់ត្រឹមត្រូវ។
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន។
- សេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អ្នកតំណាង
- សេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អភិបាលទាំងអស់
- លិខិតបញ្ជាក់គណនីនៅធនាគារ

សម្គាល់៖ នៅក្នុងការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ចំពោះរូបវន្តបុគ្គល ត្រូវបង់ចំនួន ២០.០០០៛ និងនីតិបុគ្គលបង់ ចំនួន ៥០.០០០៛។ក្រុមហ៊ុនមូលបត្រដែលវិនិយោគិនត្រូវជ្រើសរើសមានដូចជា៖

- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ (Securities Underwriter/6SF)
- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មជួញដូរមូលបត្រ (Securities Dealers/1SF)
- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មជើងសាមូលបត្រ (Securities Brokers/2SF)
- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ (Investment Advisers/2SF)

### ៣.២.២. ការបើកគណនីជួញដូរ

ការបើកគណនីជួញដូរគឺសំដៅដល់ការបើកគណនីមូលបត្រ ព្រមទាំងគណនីសាចប្រាក់នៅនឹងក្រុមហ៊ុនមូលបត្រដែលយើងជ្រើសរើស។ បន្ទាប់ពីបានធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្ររួចវិនិយោគិនត្រូវធ្វើការបើកគណនីជួញដូរមូលបត្រ ដោយប្រើលេខអត្តសញ្ញាណវិនិយោគិន (Investor ID, មានតែមួយគត់សម្រាប់វិនិយោគិនម្នាក់ មានរយៈពេល ១០ឆ្នាំ) ដែលត្រូវបានផ្តល់ឱ្យដោយ**គ.ម.ក** ។ ជាការអនុវត្តក្រុមហ៊ុនមូលបត្រជាមួយអ្នកធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិននេះជូនអតិថិជនរបស់ខ្លួន ដោយយកឬមិនយកកម្រៃបន្ថែមលើ ២០.០០០រៀល ចំពោះរូបវន្តបុគ្គល និង ចំពោះនីតិបុគ្គល ចំនួន ៥០.០០០រៀលដែលតម្រូវដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់យ៉ាងហោចណាស់មួយរយភាគរយ(សម្រាប់ការបញ្ជាទិញ) ឬបរិមាណមូលបត្រយ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់ការបញ្ជាលក់)។ នៅពេលបើកគណនីរួចហើយ វិនិយោគិនត្រូវរងចាំដល់ថ្ងៃស្អែក(ថ្ងៃធ្វើការ) ទើបអាចដាក់បញ្ជាជួញដូរបាន។ ប៉ុន្តែបច្ចុប្បន្ននៅផ្សារមូលបត្រកម្ពុជា ប្រភេទនៃការបញ្ជាគឺមានតែមួយគត់ គឺបញ្ជាមានកំណត់ (Limit Order) បញ្ជាដែលថ្លៃហ៊ានទិញខ្ពស់បំផុត ឬបញ្ជាដែលថ្លៃលក់គឺជាថ្លៃហ៊ានលក់ទាបបំផុត។

សម្គាល់៖ សូមបញ្ជាក់ជូនថាវិនិយោគិនម្នាក់អាចបើកគណនីជួញដូរតែមួយគត់នៅក្រុមហ៊ុនមូលបត្រនីមួយៗដែលគាត់ជ្រើសរើស ហើយការបើកគណនីជួញដូរសម្រាប់វិនិយោគិន សញ្ជាតិខ្មែរ និងសញ្ជាតិបរទេសគឺមានដំណើរការដូចគ្នា។

**៣.២.៣.ការដាក់បញ្ជា**

វិនិយោគិនអាចបង្គាប់ឲ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួនដាក់បញ្ជាមកកាន់ **ផ.ម.ក** ដោយបញ្ជាក់ប្រាប់យ៉ាងហោចនូវព័ត៌មានសំខាន់ៗដូចខាងក្រោម៖

១. ឈ្មោះមូលបត្រ

២.បរិមាណ

៣.ថ្លៃ

៤.ប្រភេទនៃបញ្ជាទិញ ឬបញ្ជាលក់។

វិនិយោគិនអាចបង្គាប់ទៅក្រុមហ៊ុនមូលបត្រឲ្យដាក់បញ្ជា ដោយប្រើប្រាស់មធ្យោបាយ ទំនាក់ទំនងណាមួយខាងក្រោម៖

១.ឯកសារជាលាយលក្ខណ៍អក្សរ

២.ពាក្យសំដី

៣.សារអេឡិចត្រូនិក

៤.មធ្យោបាយអេឡិចត្រូនិចដទៃទៀត។

**៣.២.៤. ប្រតិបត្តិការជួញដូរមូលបត្រ**

**ក.ម៉ោងជួញដូរ និងថ្ងៃជួញដូរ**

ការជួញដូរចាប់ផ្តើមឡើងរៀងរាល់ថ្ងៃចន្ទដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។ ផ្សារហ៊ុនចាប់បើកទទួលបញ្ជាទិញ/លក់ពីវិនិយោគិនពីម៉ោង ០៨:០០ ព្រឹក និងបិទនៅម៉ោង ១១:៣០ ព្រឹក។ ប៉ុន្តែការជួញដូរចាប់ធ្វើឡើងពីរដងគឺពីម៉ោង ០៩:០០ ដល់ម៉ោង ១១:០០ ព្រឹក និងនៅម៉ោង ១១:៣០ ព្រឹក ម្តងទៀតមុនពេលបិទផ្សារ។

**រូបភាពទី៤៖ ម៉ោងជួញដូរ និងថ្ងៃជួញដូរ**




ប្រភព៖ http://csx.com.kh/operation/market/listPosts.do?MNCD=3020

បើការបញ្ជាទិញលក់នៅលើកទីមួយម៉ោង ៩ មិនបានសម្រេចការបញ្ជានេះត្រូវបានស្តុកទុកបញ្ជានៅក្នុងការជួញដូរលើកទីពីរនៅម៉ោង ១១:៣០ ទៀតបើមិនបានសម្រេចទៀតគឺអស់សុពលភាពត្រឹមថ្ងៃបញ្ជា ឬលក់នឹង។ វិនិយោគិនអាចធ្វើការជួញដូរម្តងទៀតនៅថ្ងៃបន្ទាប់។

**ខ. សុពលភាពនៃការបញ្ជានិងការកែប្រែឬការលុបចោលការបញ្ជាដែលបានបញ្ជូន**

រាល់ការបញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក** រហូតដល់ពេលដែលការបញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

សុពលភាពនៃការបញ្ជាអាចត្រូវបានលុបក្នុងករណីដែលការជួញដូរលើមូលបត្រមួយ ត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

សមាជិកអាចកែប្រែឬលុប ថ្លៃឬបរិមាណនៃការបញ្ជាដែលបានដាក់។ នៅពេលមានការកែប្រែថ្លៃ ឬការបង្កើនបរិមាណនៃបញ្ជា ពេលវេលាបញ្ជាក់ពីការទទួលបញ្ជា (Time Stamp) ដោយប្រព័ន្ធជួញដូររបស់ **ផ.ម.ក** ត្រូវកំណត់សារជាថ្មី។

**គ. ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ**

ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅ **ផ.ម.ក.** គឺ ០១ (មួយ)ឯកតាមូលបត្រ។ បរិមាណជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការ នៅ**ផ.ម.ក.** គឺ ០១ (មួយ)ឯកតាមូលបត្រ។

ថ្លៃប្រែប្រួលទៅតាមឯកតាថ្លៃ (ឯកតាគម្លាតថ្លៃ) ដែលត្រូវបានកំណត់ដូចខាងក្រោម(ទឹកប្រាក់ទាំងអស់គិតជារៀល)។

**តារាងទី១៖ ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ**

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាទិញលក់ខុស | ឧទាហរណ៍ថ្លៃបញ្ជាទិញលក់ត្រឹមត្រូវ |
|---|---|---|---|
| ]0 – ៤.000[ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៥០ |
| [៤.000 – ២0.000[ | ២០ | ៤.២១០; ១៩.៥២៥ | ៤.២០០; ៤.២២០; ១៩.៥២០; ១៩.៥៤០ |
| [២0.000 – ៤0.000[ | ៥០ | ២០.១១០; ៣៩.៥៣០ | ២០.១០០; ២០.១៥០; ៣៩.៥០០; ៣៩.៥៥០ |
| [៤0.000 – ១00,000[ | ១០០ | ៥០.៧២០; ៩០.៤៥០ | ៥០.៧០០; ៥០.៨០០; ៩០.៤០០; ៩០.៥០០ |
| [១00.000 – ២00.000[ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៤០០; ១៥០.៦០០; ១២៥.២០០; ១២៥.៤០០ |
| [២00.000 – ៤00.000[ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| [៤00.000 – [ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

ប្រភព៖ http://csx.com.kh/operation/market/listPosts.do?MNCD=3020

ឯកតាគម្លាតថ្លៃត្រូវបានកំណត់ដូចខាងក្រោម៖

- ១០ (ដប់)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៤.០០០(បួនពាន់)រៀល ក្នុង ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។
- ២០(ម្ភៃ)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង៤.០០០ (បួនពាន់)រៀល ប៉ុន្តែទាបជាង ២០.០០០ (ពីរម៉ឺន)រៀល ក្នុង០១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។
- ៥០ (ហាសិប)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០.០០០ (ពីរម៉ឺន)រៀល ក្នុង០១ (មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។
- ១០០ (មួយរយ)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ៤០.០០០(បួនម៉ឺន)រៀល ប៉ុន្តែទាបជាង ២០០.០០០(មួយសែន)រៀល ក្នុង០១(មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។
- ២០០(ពីររយ)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃសស្មើ ឬខ្ពស់ជាង ១០០.០០០ (មួយសែន)រៀល ប៉ុន្តែទាបជាង ២០០.០០០(ពីរសែន)រៀល ក្នុង ០១(មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។
- ៥០០(ប្រាំរយ)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០០.០០០ (ពីរសែន)រៀល ប៉ុន្តែទាបជាង ៤០០.០០០(បួនសែន)រៀល ក្នុង ០១(មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។

- ១.០០០ (មួយពាន់)រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០០.០០០ (បួនពាន់)រៀល ក្នុង ០១(មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។

**ឃ.ថ្លៃមូលដ្ឋាន**

ជាទូទៅ ថ្លៃមូលដ្ឋានគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ៩០% និង១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃ IPO ដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក.)។

ក្នុងករណីដែលមានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជា ការបង្កើនឬបន្ថយមូលធន ការបែងចែកភាគលាភជាភាគហ៊ុន ការបំបែកភាគហ៊ុន ។ នោះថ្លៃមូលដ្ឋាននឹងត្រូវបានគណនាដោយស្វ័យប្រវត្តិ ដោយប្រព័ន្ធរបស់ ផ.ម.ក.តាមរយៈការប្រើប្រាស់នូវរូបមន្តមួយជាក់លាក់។

ក្នុងករណីថ្លៃមូលបត្រដែលបានគណនា ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវបង្គត់ឡើងឲ្យស្មើនឹងឯកតាគម្លាតថ្លៃ។

**ង.ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ**

ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ គឺត្រូវស្មើនឹងទឹកប្រាក់ ដែលគណនាដោយ ±៥% (បូក/ដកប្រាំភាគរយ)នៃថ្លៃមូលដ្ឋាន ហើយទឹកប្រាក់ដែលទាបជាងឯកតាគម្លាតថ្លៃត្រូវបានកាត់ខ្ទង់ចេញ។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០០(មួយពាន់) រៀល ដែនកំណត់នៃ បម្រែបម្រួលថ្លៃប្រចាំថ្ងៃគឺស្មើនឹង ៥០ (ហាសិប) រៀល។ វិនិយោគិនអាចដាក់បញ្ជាបានតែក្នុងចន្លោះនេះទេ បើដាក់ខុសពីបម្រែបម្រួលនេះនឹងមិនអាចបញ្ជាទិញ លក់បានទេ។ គេកំណត់ពី-៥% ទៅ+៥% ដើម្បីកុំឲ្យថ្លៃប្រែប្រួលខ្លាំងពេក ក្នុងន័យរក្សាស្ថេរភាពទីផ្សារ។ ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណតើចំពោះមូលបត្រកម្មសិទ្ធិ ដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតអោយជួញដូរ ក្នុងអំឡុងពេលមួយកំណត់នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ករណីដែលមូលបត្រកម្មសិទ្ធិត្រូវបានដកចេញពីការចុះបញ្ជីលក់មូលបត្រ ឬត្រូវបានព្យួរពីការជួញដូរអស់រយៈពេលវែង ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិឡើងវិញ ឬការជួញដូរមូលបត្រកម្មសិទ្ធិឡើងវិញ ត្រូវធ្វើការកំណត់ថ្លៃមូលដ្ឋានតាមវិធានកំណត់ថ្លៃមូលដ្ឋានសសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូង។

## តារាងទី២៖ ដែនកំណត់នៃបម្រែបម្រួលថ្លៃ

ឧទាហរណ៍៖ថ្លៃមូលដ្ឋាន =៣០.០០០=>៣០.០០០ x ៥% = ១.៥០០៛

៣០.០០០៛ + ១.៥០០៛= ៣១.៥០០៛

៣០.០០០៛ - ១.៥០០៛= ២៨.៥០០

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ(+៥%) | ៣១.៥០០៛ | |
| | ៣១.៤៥០៛ | |
| | : | |
| | ៣០.០៥០៛ | |
| ថ្លៃមូលដ្ឋាន | ៣០.០០០៛ | ឯកតាគម្លាតថ្លៃ ៥០៛ |
| | ២៩.៩៥០៛ | |
| | : | |
| | ២៨.៥៥០៛ | |
| ដែនកំណត់ថ្លៃខាងក្រោម(-៥%) | ២៨.៥០០៛ | |

### ច.គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរ ត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ (Single Price Auction)។

អាទិភាពនៃបញ្ជាទិញ និងបញ្ជាលក់តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម៖

- បញ្ជាលក់ដែលមានថ្លៃទាបជាង (មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង) ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង (មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង)។

➤ ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

## តារាងទី៣៖ គោលការណ៍ដេញថ្លៃ

ឧទាហរណ៍៖ គោលការណ៍ដេញថ្លៃ

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | : | |
| | ៦.៥២០ | ៥០០① |
| | ៦.៥០០ | ១០០② ២០០③ |
| : | ៦.៤៨០ | : |
| : | ៦.៤៦០ | : |
| ៣០០③ ២០០② | ៦.៤២០ | |
| (ថ្លៃលក់ទាបបំផុត) ៤៥០① | ៦.៤០០ | |
| | : | |

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ(១) និងបញ្ជាលក់(១) ត្រូវបានអនុវត្តមុន ស្របទៅតាមអាទិភាពថ្លៃ។ ហើយក្នុងចំណោមបញ្ជាដែលមានថ្លៃស្មើគ្នា បញ្ជា(២) ដែលទទួលបានមុន ត្រូវបានអនុវត្តមុនបញ្ជា(៣)។

កំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា:

- ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម៖

  ក.រាល់បញ្ជាទិញដែលមានថ្លៃស្មើនឹងដែនកំណត់ថ្លៃខាងលើ (ថ្លៃមូលដ្ឋាន +៥%)

  ខ.រាល់បញ្ជាលក់ដែលមានថ្លៃស្មើនឹងដែនកំណត់ថ្លៃខាងក្រោម (ថ្លៃមូលដ្ឋាន -៥%)

- ចំពោះបញ្ជាព្រមពេលគ្នាដូចមានចែងក្នុងចំណុច១នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះបញ្ជាដែលមានបរិមាណច្រើនជាង មានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណី បញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល ផ.ម.ក ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

- ការបែងចែកបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នាដូចមានចែងនៅក្នុងចំនុច ១ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចមានចែងក្នុងចំនុច ២ នៃកថាខណ្ឌដូចខាងក្រោម៖

  ក.១០០ (មួយរយ)ដង នៃឯកតាជួញដូរ។

  ខ.៥០០ (ប្រាំរយ)ដង នៃឯកតាជួញដូរ។

គ.១០០០(មួយពាន់)ដង នៃឯកតាជួញដូរ។

ឃ.៥០(ហាសិប)ដង នៃបរិមាណដែលនៅសល់។ ក្នុងករណីនេះ ប្រសិនបើបរិមាណនោះទាប ជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

ង.បរិមាណដែលនៅសល់ទាំងអស់ ត្រូវផ្តល់អោយតាមអាទិភាព។

**ឆ.វិធីសាស្ត្រ និងយន្តការនៃការអនុវត្តការជួញដូរ**

រាល់ការជួញដូរ ត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ**

គោលការណ៍៖

១. បញ្ជាទាំងអស់ត្រូវជួញដូរនៅថ្លៃតែមួយ និងត្រូវរង់ចាំដល់ម៉ោងជួញដូរ

២. ថ្លៃផ្គូផ្គងជាថ្លៃដែលអាចផ្គូផ្គងនៅបរិមាណច្រើនបំផុត

ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

**តារាងទី៤៖ ដេញថ្លៃដោយយកថ្លៃតែមួយ**

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❸ ~~700~~ (100) |
| ❷ ~~200~~ | 10,300 | |
| ❹ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ប្រភព៖ http://csx.com.kh/operation/market/listPosts.do?MNCD=3020

ម៉ោងជួញដូរ (ម៉ោង ០៩ : 00 ឬ ១១: ៣០)៖

600 x 10400៛ = 6,240,000៛

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន**

គោលការណ៍៖

១. បញ្ជានីមួយៗអាចជួញដូរនៅថ្លៃច្រើនខុសៗគ្នា និងអាចជួញដូរបានភ្លាមៗនៅពេលដែលមានបញ្ជាត្រូវគ្នា

២. នៅពេលបញ្ជាទិញ និងលក់ត្រូវគ្នាថ្លៃផ្គូផ្គង់ត្រូវជ្រើសយកថ្លៃរបស់បញ្ជាដែលទទួលបានមុន

**តារាងទី៥៖ ដេញថ្លៃដោយយកថ្លៃច្រើន**

ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ 300 | 10,400 | ❸ 700 100 |
| ❷ 200 | 10,300 | |
| ❹ 100 | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ម៉ោងជួញដូរ(09:00-11:00 ព្រឹក)

1. 200 x 10,300 ៛ = 2,060,000 ៛ (ភាមៗ)
2. 300 x 10,400 ៛ = 3,120,000 ៛ (ភ្ញាមៗ)
3. 100 x 10,400 ៛ = 1,040,000 ៛ (ភ្ញាមៗ)

6,220,000 ៛

ប្រភព៖ http://csx.com.kh/operation/market/listPosts.do?MNCD=3020

### ៣.២.៥. ដំណើរការនៃការទិញ-លក់មូលបត្រ

បន្ទាប់ពីវិនិយោគិនបានស្វែងយល់នូវព័ត៌មានមុនការអនុវត្តការជួញដូររួចដូចជា បើកលេខអត្តសញ្ញាណវិនិយោគិន ការបើកគណនីជួញដូរ ជ្រើសរើសក្រុមហ៊ុនមូលបត្រនិងព័ត៌មានមួយចំនួនទៀតវិនិយោគិនអាចធ្វើការជួញដូរបាន៖

**ថ្ងៃជួញដូរ (T+0)**

- មុនការជួញដូរវិនិយោគិនត្រូវបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូរ របស់ក្រុមហ៊ុនមូលបត្រឲ្យបានមុនម៉ោងជួញដូរ។
- ម៉ោងជួញដូរនៅ **ផ.ម.ក** ត្រូវបានបែងចែកជាពីរវគ្គ។ វគ្គទី១ ចាប់ផ្តើមពីម៉ោង ៨:00 ដល់ម៉ោង ៩:00 ព្រឹក និងវគ្គទី២ ចាប់ផ្តើមពីម៉ោង ៩:00 ដល់ម៉ោង ១១:៣០ ព្រឹក។
- ការទទួលបញ្ជាទិញ ឬលក់មូលបត្រគឺចាប់ពីម៉ោង ៨:00 នាទីព្រឹកប៉ុន្តែការអនុវត្តការជួញដូរ គឺធ្វើឡើងចំនួន ២ ដង គឺនៅម៉ោង ៩:00 ព្រឹកម្តង និងម៉ោង ១១:00 នាទីព្រឹកម្តងទៀត។ ក្រោយពីការជួញដូរត្រូវបានបញ្ចប់នៅម៉ោង ១១:៣០នាទីព្រឹកនៃថ្ងៃជួញដូរ (T+0) រហូតដល់មុនម៉ោង ១២:00 នាទីថ្ងៃត្រង់ នៃថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ(T+១) គឺជាកំឡុងពេលសម្រាប់កែបញ្ជាទិញឬលក់មូលបត្រ។

**មួយថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+១)**

- ពីម៉ោង ១២:១៥នាទីថ្ងៃត្រង់ ប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់(ផ.ម.ក) ប្រព័ន្ធចាប់ផ្តើមធ្វើការផាត់ទាត់សាច់ប្រាក់ និងមូលបត្រដើម្បីរកលទ្ធផលនៃចំនួនសាច់ប្រាក់ និងមូលបត្រដែលវិនិយោគិនម្នាក់ៗត្រូវទទួលបាន។
- ពីម៉ោង ១:៣០ទៅដល់ម៉ោង ២:៣០នាទីថ្ងៃត្រង់ ឬមុនម៉ោង ២:៣០នាទីថ្ងៃត្រង់ ប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់ (ផ.ម.ក)ចេញសេចក្តីណែនាំសម្រាប់ធ្វើការទូទាត់ ទៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Securities Exchange) និងក្រុមហ៊ុនមូលបត្រ។ ការចេញសេចក្តីណែនាំសម្រាប់ធ្វើការទូទាត់សាច់ប្រាក់ គឺត្រូវធ្វើជាស្វ័យប្រវត្តិដោយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក** តាមរយៈដំណើរការប្រព័ន្ធ Batch Processing។ ដំណើរការប្រព័ន្ធ Batch Files (Soft Copy) សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធ និងដើម្បីធ្វើការទូទាត់។

**ពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+២)**

- មុនម៉ោង ៨:៣០នាទីព្រឹក ក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញផ្ទេរសាច់ប្រាក់ពីគណនីក្រុមហ៊ុនមូលបត្រចូលទៅក្នុងគណនីរបស់ប្រតិបត្តិករផាត់ទាត់និងទូទាត់មូលបត្រ (CSO ACC)
- ម៉ោង ១០:៣០នាទីព្រឹក សាច់ប្រាក់ត្រូវបានផ្ទេរពីគណនីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) ទៅក្នុងគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់។ ស្របពេលជាមួយគ្នា មូលបត្រត្រូវបានផ្ទេរពីគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់ទៅគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញ តាមរយៈគណនីមូលបត្ររបស់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ(CSO ACC)។

## រូបភាពទី៥៖ គំនូសតាងដំណើរការជួញដូរមូលបត្រ




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយ នៅមួយថ្ងៃមុនថ្ងៃជួញដូរ។

(២)វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រ ជាលាយលក្ខណ៍អក្សរ ពាក្យសំដី (ថតទុក) ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ **ផ.ម.ក.** ប៉ុន្តែមុននឹងដាក់បញ្ជាក្រុមហ៊ុនមូលបត្របានបង្កកទុករួចហើយនូវសាច់ប្រាក់ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយនៃបញ្ជានីមួយៗ។

(៤) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦)ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗ របស់ខ្លួន (នៅ T+0)។

(៧) ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+១។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែងគឺក្រុមហ៊ុនមូលបត្រប្រើប្រាស់សាច់ប្រាក់ ឬមូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ ដោយសុំឬមិនបាច់សុំការអនុញ្ញាតពីអតិថិជនឡើយ។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ **ផ.ម.ក.**។

### ៣.២.៦. ប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់

ការផាត់ទាត់ អាចនិយាយបានថាជាការរៀបចំ និង ព្រមព្រៀងលើការជួញដូរមូលបត្រតាមរយៈការផ្ទៀងផ្ទាត់ស្របទៅនឹងបរិមាណ និងថ្លៃបញ្ជាទិញលក់ ការកត់ត្រា និងការផ្តល់ព័ត៌មានដើម្បីធ្វើការទូទាត់បន្ត។

ការផាត់ទាត់គឺជាលំដាប់នៃដំណើរការដែល Central Counter-party (CCP)ចាត់ចែងធានាលើការទូទាត់ដោយការបន្សុទ្ធ ឬកាត់កង netting ឥណទាន និងបំណុលទាំងឡាយរវាងអ្នកលក់ និងអ្នកទិញ។

Central Counter- party (CCP)សំដៅលើអង្គភាពដែលទទួលយកកាតព្វកិច្ចជាអ្នកទិញចំពោះអ្នកលក់ទាំងអស់ និងជាអ្នកលក់ចំពោះអ្នកទិញទាំងអស់។ តាមវិធីនេះ អ្នកទិញ និងអ្នកលក់មិនមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះគ្នាទៅវិញទៅមកទេ ផ្ទុយទៅវិញត្រូវមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះ CCP។ ក្នុងករណីនេះផ្សារមូលបត្រកម្ពុជា (ផ.ម.ក)មានតួនាទីជា CCPនៅក្នុងផ្សារមូលបត្រកម្ពុជា។

**រូបភាពទី៦៖ អន្តរាគមន៍នៃ ផ.ក.ម**




ប្រភព៖ http://csx.com.kh/operation/clearing/listPosts.do?MNCD=3030

**ការបន្សុទ្ធ ឬការកាត់កង (Netting):** គឺជាដំណើរការនៃការកាត់បន្ថយកាតព្វកិច្ចឥណពន្ធរបស់អ្នកជួញដូរជាច្រើន ពីចំនួនច្រើនទៅចំនួនតិច។ តាមរយៈការបន្សុទ្ធ ផ.ម.ក. គណនាទំហំ

ដែលត្រូវទូទាត់ចុងក្រោយ។ បន្ទាប់ពីការបន្សុទ្ធ កាតព្វកិច្ចឥណទាន ឬឥណពន្ធដើមត្រូវបាន ជំនួសដោយកាតព្វកិច្ចឥណទានឬឥណពន្ធតែមួយ។ ទំហំដែលត្រូវទូទាត់ចុងក្រោយ ត្រូវបាន គណនាតាមរបៀបដូចខាងក្រោមៈ

- ករណីមូលបត្រ៖ ទទួលបានដោយធ្វើការបន្សុទ្ធបរិមាណបានលក់សរុប និងបរិមាណបាន ទិញសរុប ចំពោះប្រភេទមូលបត្រមួយ និងចំពោះសមាជិកនីមួយៗ។
- ករណីសាច់ប្រាក់៖ ទទួលបានដោយធ្វើការផាត់ទាត់តម្លៃបានទិញសរុប និងតម្លៃបានលក់ សរុបចំពោះសមាជិកនីមួយៗ។

**អ្វីទៅជាការទូទាត់?**

ការទូទាត់មូលបត្រ គឺជាការដោះដូរសាច់ប្រាក់ និងមូលបត្រ ជាមួយនឹងការផ្ទេរភាពជាម្ចាស់ កម្មសិទ្ធិនៃសាច់ប្រាក់ និងមូលបត្រនោះ។

ការទូទាត់គឺជាការបញ្ចប់ប្រតិបត្តិការ ដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យ អ្នកទិញហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។

**លក្ខណៈនៃការទូទាត់របស់ ផ.ម.ក.៖**

- វីធីសាស្ត្រនៃការទូទាត់៖ DVP3 (ការប្រគល់មូលបត្រ ថ្នូរនឹងសាច់ប្រាក់គំរូទី៣) DVP3 ជាដំណើរការនៃការប្រគល់មូលបត្រ ដែលត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នា នៃការប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (បន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ ប្រាក់) ។វាត្រូវបានកើតឡើងនៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការ។
- ពេលវេលានៃការទូទាត់៖ម៉ោង៨និង៣០នាទីព្រឹក(T+2)សមាជិកត្រូវផ្ទេរមូលបត្រ និង សាច់ប្រាក់ដែលត្រូវទូទាត់ទៅគណនីរបស់ ផ.ម.ក. នៅមុនម៉ោង ៨:៣០ព្រឹក នៅកាល បរិច្ឆេទទូទាត់ ហើយផ.ម.ក. ត្រូវទូទាត់មូលបត្រ និងសាច់ប្រាក់បន្តទៅឲ្យសមាជិកដែល ត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។
- ភ្នាក់ងារទូទាត់សាច់ប្រាក់ (ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និង ធនាគារ BIDC) មានតួនាទីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

### រូបភាពទី៧៖ គំនូសបំព្រួញអំពីពេលវេលានៃការជាត់ទាត់ និងទូទាត់




ប្រភព៖ http://csx.com.kh/operation/clearing/listPosts.do?MNCD=3030

### យន្តការនៃការជាត់ទាត់និងទូទាត់

-នៅ (T+0) ក្រោយពីបិទការជួញដូរនៅម៉ោង ១១:៣០នាទីក្រុមហ៊ុនមូលបត្រទាំងអស់ត្រូវបិទ Leger នៅត្រឹមម៉ោង ៣:០០រសៀល។ បន្ទាប់មក ក្រុមហ៊ុនមូលបត្រ ត្រូវផ្ទៀងផ្ទាត់លទ្ធផលនៃការជួញដូរប្រចាំថ្ងៃរបស់ខ្លួន។ ស្របពេលជាមួយគ្នានេះប្រតិបត្តិករជាត់ទាត់និងទូទាត់ (CSO) ធ្វើការជាត់ទាត់បរិមាណមូលបត្រនិងបរិមាណសាច់ប្រាក់សរុបរបស់ក្រុមហ៊ុនមូលបត្រនីមួយៗ។

-នៅ T+១ បន្ទាប់ពីម៉ោង ១២:៣០នាទីថ្ងៃត្រង់ CSO នឹងផ្ញើបញ្ជាទូទាត់ទៅក្រុមហ៊ុនមូលបត្រនិងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។ យ៉ាងយូរត្រឹមម៉ោង ៥:00រសៀល ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្របានយកបញ្ជាទូទាត់ជា Hard Copy ពីCSO។

-នៅ T+២: មុនម៉ោង ០៨:៣០នាទីព្រឹកCSO នឹងធ្វើការពិនិត្យលើការផ្ទេរសាច់ប្រាក់ពីគណនីរបស់ក្រុមហ៊ុនមូលបត្រ (SF)អ្នកទិញទៅគណនីទូទាត់របស់ខ្លួន។ ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវធ្វើតាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)ដែលយន្តការនៃការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្របែងចែកជាពីរប្រភេទ៖

- ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ៖ ក្រុមហ៊ុនមូលបត្រ(អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិការជាត់ទាត់(CSO)។ បន្ទាប់មក CSOត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាាច់ប្រាក់របស់ SF (អ្នកលក់) ដោយប្រតិបត្តិការនេះធ្វើឡើងនៅថ្ងៃ T+២។
- ការទូទាត់សាច់ប្រាក់អន្តរធនាគារ មានន័យថាជាការទូទាត់ឆ្លងធនាគារដោយវិនិយោគិនជាអ្នកទិញ និងវិនិយោគិនជាអ្នកលក់មានគណនីសាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រផ្សេងគ្នា៖ ក្រុមហ៊ុនមូលបត្រ (អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពី

គណនីសាច់ប្រាក់របស់ខ្លួននៅ CSA1(ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករផាត់ទាត់និងទូទាត់។ បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាច់ប្រាក់របស់ SF(អ្នកលក់) ដែលបើកនៅក្នុងCAS2 តាមរយៈសភាផាត់ទាត់នៃNBC។

ក្រោយពីកាត់កងរួច SF ដែលត្រូវយក Credit advice ទៅNBCយ៉ាងយូរបំផុតនៅម៉ោង ៩ ព្រឹក។ CSOទទួលសាច់ប្រាក់ និង Settleនៅម៉ោង ១០:៣០នាទី។ ក្រោយម៉ោង ១០:៣០នាទី សាច់ប្រាក់នោះនឹងបង្វែចូលក្នុងគណនីរបស់SF។

**រូបភាពទី៨៖ គំនូសតាងដំណើរការផាត់ទាត់និងទូទាត់មូលបត្រ**




(១) SF(អ្នកលក់) ត្រូវផ្ទេរមូលបត្រ (Book-entry Transfer)ពីគណនីមូលបត្ររបស់ខ្លួនទៅគណនីទូទាត់មូលបត្ររបស់ CSO ។

(២) CSOត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីមូលបត្រ របស់SF(អ្នកទិញ)នៅពេល Settle គឺសាច់ប្រាក់ និងមូលបត្រត្រូវបានផ្ទេរទៅកាន់គណនីរបស់SF។

### ៣.២.៧.ប្រតិបត្តិការរក្សាទុកមូលបត្រ

មូលបត្រត្រូវបានរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រ តាមរយៈការកត់ត្រាចំនួនមូលបត្រក្នុងគណនីមូលបត្រនីមួយៗ។ មូលបត្រត្រូវបានរក្សាទុកដោយប្រព័ន្ធព័ត៌មានវិទ្យា ហើយមិនមានមូលបត្រជារូបវន្តទេ។

**យន្តការរក្សាទុកមូលបត្រ**

**តើការរក្សាទុកមូលបត្រគឺជាអ្វី?**

- ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី

(Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

**អត្ថប្រយោជន៍**

- នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry)ដោយគ្មានការផ្ទេរមូលបត្ររូបវន្ត។ ដូច្នេះហានិភ័យចំពោះការបាត់ និង ការលួចមូលបត្រត្រូវបានជៀសវាងទាំងស្រុង។
- សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ **ផ.ម.ក.** មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

**ការបើកគណនី**

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger (ledger system) របស់ **ផ.ម.ក.** ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

**ការដាក់ផ្ញើមូលបត្រ**

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ :

- ✓ ប្រភេទមូលបត្រ
- ✓ ចំនួននៃការបោះផ្សាយ
- ✓ ឈ្មោះមូលបត្រ
- ✓ អក្សរកូដ
- ✓ ចំនួនមូលបត្រសរុប
- ✓ កាលបរិច្ឆេទបោះផ្សាយ
- ✓ កាលបរិច្ឆេទចុះបញ្ជី
- ✓ ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ

## ៣.៣.ការវិវត្តនៃកិច្ចដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ

### ៣.២.១ ប្រព័ន្ធជួញដូរតាមទូរស័ព្ទដៃ

តាមរយៈវត្តមានមូលបត្រនៅក្នុងប្រទេសកម្ពុជា ប៉ុន្មានឆ្នាំមកនេះ យើងសង្កេតឃើញថា មានការកើនឡើងចំនួនក្រុមហ៊ុនចុះបញ្ជី ប៉ុន្តែចំនួននៃអ្នកជួញដូរនូវមានកម្រិត។ ម៉្យាងវិញទៀត ចំណេះដឹងដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ របស់ប្រជាជនកម្ពុជា និងវិនិយោគិននៅក្នុងប្រទេសក៏នៅមិនទាន់យល់ច្បាស់។ **ផ.ម.ក** បានសិក្សាស្រាវជ្រាវ ដើម្បីរកវិធីសាស្ត្រក្នុងការបង្កើនយន្តការជួញដូរលើវិស័យមួយនេះ។ យោងតាមស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺមានការរីកចម្រើនយ៉ាងខ្លាំង លើប្រព័ន្ធបច្ចេកវិទ្យា ជាពិសេស ទូរស័ព្ទដៃទំនើបៗ ដែលមាន មុខងារជាច្រើនងាយស្រួលក្នុងការប្រើប្រាស់។ ក្នុងទិសដៅដើម្បីជំរុញនូវសន្ទនីយភាពនៅក្នុងទីផ្សារ ក៏ដូចជាការឆ្លើយតបទៅនឹងភាពរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា តាមរយៈការផ្តល់នូវប្រព័ន្ធជួញដូរមួយដែលមានលក្ខណៈងាយស្រួល និងថ្លៃសេវាទាប ការជួញដូរទូរស័ព្ទនឹងត្រូវបានដាក់ឱ្យដំណើរការនៅក្នុងផ្សារមូលបត្រកម្ពុជា។ ប្រព័ន្ធជួញដូរថ្មីនេះ មានភាពងាយស្រួល និងរហ័សជាងប្រព័ន្ធជួញដូរបច្ចុប្បន្ន ព្រោះអតិថិជនទាំងអស់អាចធ្វើការបញ្ជាទិញ-លក់មូលបត្រដោយខ្លួនឯងបាន ដោយមិនចាំបាច់ធ្វើការបញ្ជាតាមរយៈអន្តរការីមូលបត្រនោះទេ តែការដាក់បញ្ជានេះ នឹងឆ្លងកាត់តាមប្រព័ន្ធរបស់ក្រុមហ៊ុនអន្តរការីមូលបត្រ។ ដោយប្រតិបត្តិការ មិនចាំបាច់ធ្វើឡើងតាមរយៈអន្តរការីមូលបត្រ នាំឱ្យកម្រៃសេវានៃការជួញដូរ គឺទាបជាងថ្លៃសេវានាពេលបច្ចុប្បន្ន។ ដោយយោងតាមលោក **ឡាមួន សូឡី** ជានាយកប្រតិបត្តិការទីផ្សារនៃក្រុមហ៊ុនផ្សារមូល បត្រកម្ពុជា ប្រព័ន្ធនេះនឹងត្រូវដាក់ឱ្យដំណើរការនៅចុងឆ្នាំ ២០១៧ នេះ។

**អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធជួញដូរតាមទូរស័ព្ទ**

- បង្កើនទំហំទីផ្សារ
- ងាយស្រួលដល់វិនិយោគិនក្នុងការតាមដានព័ត៌មានជួញដូរនៅលើទីផ្សារ
- វិនិយោគិនអាចធ្វើការជួញដូរមូលបត្រនៅលើទីផ្សារបានដោយខ្លួនឯង
- មានសន្ទនីយភាពជាងមុន
- អាចធ្វើការស្នើរសុំដកដាក់ប្រាក់ និងដឹងពីព័ត៌មានតុល្យភាពសាច់ប្រាក់បានដោយខ្លួនឯង

### ៣.២.២.កិច្ចដំណើរការសមាហរណកម្មទីផ្សារមូលបត្រក្នុងតំបន់អាស៊ាន

ជាការឆ្លើយតបទៅនឹងការធ្វើសមាហរណកម្មអាស៊ាន វេទិកាទីផ្សារមូលធនអាស៊ានត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ដែលមានសមាជិកជានិយ័តករនៃប្រទេសទាំង ១០ របស់អាស៊ាន។

វេទិកានេះ ត្រូវបានបង្កើតឡើងដើម្បីជំរុញនូវការធ្វើសមាហរណកម្មបទប្បញ្ញត្តិ។ តាមរយៈទិសដៅការងារនេះ ក៏ដូចជាក្នុងគោលបំណងជំរុញការជួញដូរនៅក្នុងផ្សារមូលបត្រកម្ពុជា ការដាក់ឱ្យដំណើរការនូវការជួញដូរមូលបត្រឆ្លងដែន នឹងត្រូវដាក់ឱ្យដំណើរការនៅក្នុងផ្សារមូលបត្រកម្ពុជា ដែលមានន័យថាវិនិយោគិនកម្ពុជាអាចវិនិយោគនៅក្នុងផ្សារភាគហ៊ុនបរទេស ហើយវិនិយោគិនបរទេសក៏អាចធ្វើការវិនិយោគនៅក្នុងផ្សារមូលត្រកម្ពុជាផងដែរ។

## ៣.៣.ការវិភាគលើភាពខ្លាំង ភាពខ្សោយ

យោងទៅតាមទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធនឹងដំណើការនៅផ្សារមូលបត្រកម្ពុជា ឃើញថាទីផ្សារនេះមានចំណុចខ្លាំង និងចំនុចខ្សោយមួយចំនួនដូចជាៈ

❖ **ភាពខ្លាំង**

- ក្រុមហ៊ុនដែលចុះបញ្ជីសុទ្ធសឹងជាក្រុមហ៊ុនធំៗ មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងមានតម្លាភាព ដែលជាមូលដ្ឋានគ្រឹះទ្រទ្រង់ទីផ្សារ។
- ច្បាប់និងបទប្បញ្ញត្តិនានាមានលក្ខណៈរឹងមាំដើម្បីគ្រប់គ្រង និងការពារហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងក្នុងវិស័យមូលបត្រ។
- **គ.ម.ក.** បានធ្វើការកែតម្រូវលើលក្ខខណ្ឌមួយចំនួន ដើម្បីផ្តល់ឱកាសឲ្យសហគ្រាសធុនតូចនិងមធ្យមមានលទ្ធភាពអាចចុះបញ្ជីនៅ **ផ.ម.គ.** បានក្នុងការស្វែងរកហិរញ្ញប្បទានរយៈពេលវែងសម្រាប់ពង្រីកដំណើរការអាជីវកម្ម។
- **ផ.ម.ក.** បានបង្កើតវគ្គបណ្តុះបណ្តាលទាក់ទងនឹងមូលបត្រជារៀងរាល់ខែ និងសិក្ខាសាលាផ្សេងៗទៀត ដែលជួយបណ្តុះបណ្តាសាធារណជនឲ្យមានការចាប់អារម្មណ៍ និងមានការយល់ដឹងពីវិស័យមូលបត្រនេះកាន់តែច្រើន។
- មានប្រព័ន្ធជួញដូរច្បាស់លាស់ ដែលធានាមិនឲ្យមានការបាត់បង់មូលបត្រឬសាច់ប្រាក់។

❖ **ភាពខ្សោយ**

- ជម្រើសក្នុងការវិនិយោគមានចំនួនតិចនៅឡើយ ហើយទំហំនៃការជួញដូរមានការថយចុះ។
- ដំណើរការក្នុងការចុះបញ្ជីមានភាពស្មុគស្មាញ ចំណាយពេលវេលាយូរ និងថវិការច្រើន។
- វិធីសាស្ត្រក្នុងការចុះឈ្មោះជាវិនិយោគិន មិនទាន់មានភាពងាយស្រួលនៅឡើយ ដោយពួកគេត្រូវទៅទាក់ទងដល់ក្រុមហ៊ុនមូលបត្រផ្ទាល់ ទោះបីជាពួកគេនៅតាមបណ្តាខេត្តក៏ដោយ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងនិងប្រធានបទ "ដំណើរការប្រតិបត្តិការទីផ្សារមូលបត្រឆ្ពោះទៅពេលអនាគត" រួចមកលទ្ធផលដែលទទួលបានបង្ហាញអោយឃើញថា ដំណើរការនៃការជួញដូរមូលបត្រនៅកម្ពុជាគឺមានលក្ខណៈក្មេងខ្ចីនៅឡើយ។ មកដល់ពេលនេះ មានតែក្រុមហ៊ុនចំនួនប្រាំប៉ុណ្ណោះ ដែលបានធ្វើការចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រ។ ជាក់ស្តែង ដូចដែលបានបកស្រាយនៅក្នុងជំពូក៣ ដំណើរការនៃការជួញដូរមូលបត្រមិនមានភាពស្មុគស្មាញប៉ុន្មាននោះទេសម្រាប់វិនិយោគិន ដោយក្នុងនោះវិនិយោគិនគ្រាន់តែធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្រមួយដែលខ្លួនពេញចិត្ត ដើម្បីធ្វើជាតំណាងក្នុងការជួញដូរមូលបត្រជំនួសសមីខ្លួន ដែលហៅថាឈ្មួញជើងសារ នៅផ្សារមូលបត្រ បន្ទាប់មកវិនិយោគិនអាចបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រនោះ និងធ្វើការដាក់បញ្ជាដោយភ្ជាប់ទៅជាមួយនូវព័ត៌មានលម្អិតផ្សេងៗដូចជាប្រភេទនៃបញ្ជាទិញឬលក់ ឈ្មោះមូលបត្រ ថ្លៃជួញដូរ បរិមាណមូលបត្រជាដើម ទៅកាន់ក្រុមហ៊ុនមូលបត្រដើម្បីអាចចាប់ផ្តើមការជួញដូរបាន។ បន្ទាប់ពីបញ្ជាត្រូវបានបញ្ចូលទៅកាន់ផ្សារមូលបត្រកម្ពុជា នោះក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងទទួលខុសត្រូវក្នុងការធ្វើប្រតិបត្តិការសំខាន់ៗទាំងបីរួមមាន ប្រតិបត្តិការទីផ្សារ ប្រតិបត្តិការផាត់ទាត់ និងទូទាត់ព្រមទាំងប្រតិបត្តិការរក្សាទុកមូលបត្រប្រកបដោយតម្លាភាព ប្រសិទ្ធិភាព និងភាពត្រឹមត្រូវ។ ម៉្យាងទៀត គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងរៀបចំ យុទ្ធសាស្ត្រនានាដើម្បីទាក់ទាញវិនិយោគិន និងសាធារណៈជនទូទៅឲ្យចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជាតាមរយៈការលើកទឹកចិត្ត និងបង្កើតច្បាប់នានា។

ទន្ទឹមនឹងនេះ ដើម្បីធ្វើអោយដំណើរការជួញដូរមូលបត្រមានភាពងាយស្រួល និងប្រកបដោយសុច្ចរិត គណៈកម្មការមូលបត្រកម្ពុជាដែលជាស្ថាប័នអាជ្ញាធរគ្រប់គ្រងវិស័យមូលបត្រនៅកម្ពុជាបានចែងជាច្បាប់ បទប្បញ្ញត្តិ អនុក្រឹត្យ ក៏ដូចជាប្រកាសផ្សេងៗដែលតម្រូវឲ្យវិនិយោគិន ក្រុមហ៊ុនផ្សារមូលបត្រ ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ធ្វើការអនុវត្តតាម ដើម្បីជៀសវាងនូវការជួញដូរមិនស្មោះត្រង់ និងបញ្ហាផ្សេងៗទៀត។

សរុបសេចក្តីមក ការអភិវឌ្ឍផ្សារមូលបត្រនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងវិស័យហិរញ្ញវត្ថុ ដែលជាមូលដ្ឋានគ្រឹះក្នុងការជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ មិនតែ

ប៉ុណ្ណោះក៏ជួយសម្រួលដល់ក្រុមហ៊ុនសាជីវកម្ម ម្ចាស់សហគ្រាស និងក្រុមហ៊ុនដទៃទៀតដែលខ្វះខាតទុន ដោយធ្វើការប្រមូលដើមទុនពីវិនិយោគិន ដើម្បីធ្វើការអភិវឌ្ឍក្រុមហ៊ុនរបស់ខ្លួនក៏ដូចជាបង្កើតការងារមួយចំនួនថ្មីសម្រាប់ប្រជាពលរដ្ឋនិងជៀសផុតពីភាពក្រីក្រ។ ជាពិសេសទីផ្សារមូលបត្របានជំរុញវិស័យហិរញ្ញវត្ថុឲ្យមានការរីកចំរើនជាលំដាប់ ដោយចាប់ផ្តើមពីក្រុមហ៊ុនបោះផ្សាយ ការលក់ទៅឲ្យវិនិយោគិន និងនៅក្នុងទីផ្សារដំបូងនិងទីផ្សារបន្ទាប់។

## ២.អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកឃើញថាទីផ្សារមូលបត្រកម្ពុជាមានចំណុចខ្វះខាតមួយចំនួនដែលរាំងស្ទះដល់ដំណើរប្រព្រឹត្តទៅនៃទីផ្សារ។ ហេតុដូច្នេះហើយក្រុមយើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីចូលរួមចំណែកក្នុងការកែលម្អ និងអភិវឌ្ឍន៍ទីផ្សារ។ មតិយោបល់ទាំងនេះមានដូចខាងក្រោម៖

**គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

- គួរមានការកែសម្រួលលើវិធីសាស្ត្រនៃការចុះបញ្ជីរបស់ក្រុមហ៊ុនបោះផ្សាយ ដើម្បីជំរុញប្រតិបត្តិការជួញដូរ ថែមទាំងកាត់បន្ថយទាំងពេលវេលា និងថវិការទៀតផង។
- គួរបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលពីវិស័យមូលបត្រឲ្យបានច្រើន តាមស្ថាប័នអប់រំ និងការងារ ទាំងនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ដើម្បីបង្កើនការយល់ដឹង និងភាពជឿជាក់មកលើផ្សារមូលបត្រ។
- លើកទឹកចិត្តបន្ថែម ចំពោះសហគ្រាស ឬក្រុមហ៊ុនដែលមានសក្តានុពល ឲ្យចូលរួមក្នុងទីផ្សារមូលបត្រតាមរយៈការដាក់ចេញនូវគោលនយោបាយ និងលក្ខខណ្ឌលើកទឹកចិត្តដ៏ល្អប្រសើរសម្រាប់ពួកគេ
- គួរបើកចំហរនូវព័ត៌មានឲ្យបានទូលំទូលាយ ទៅក្រុមហ៊ុន ឬវិនិយោគិន ដើម្បីងាយស្រួលក្នុងការវិនិយោគ។

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន,២០០៧
- ច្បាប់ស្តីពី មូលបត្ររដ្ឋដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ 2006
- គោលការណ៍ណែនាំ លេខ ០០១ គ.ម/គ.ណ.ន. ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន
- ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ, លេខ ០១១ គ.ម.ក/ប្រ.ក.ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០៩

## 🕮 សៀវភៅ

- សាស្ត្រាចារ្យ ញាន វណ្ណៈ,២០០៩,ហិរញ្ញប្បទានរបស់របស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយៈទីផ្សារមូលបត្រ
- សាស្ត្រាចារ្យ សួន ចំរើន,ឆ្នាំសិក្សា ២០១៥-២០១៦  ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- ស៊ូ សុជា,អ៊ុំង នីតា ២០១៥ , ការវិនិយោគលើមូលបត្រនៅមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន
- បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ,២០១១
- ហ៊ាង បទុម្ម និង ហង់ ពិសី ២០១៤, យន្តការនៃការផាត់ទាត់និងទូទាត់មូលបត្រកម្មសិទ្ធិ

## គេហទំព័រ

- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុចា (CSX) www.csx.com.kh/main.do
- គណៈកម្មការមូលបត្រកម្ពុជា (SECC) www.secc.gov.kh
- http://www.secc.gov.kh/khmer/faq.php?pn=2 (ថតចម្លងនៅថ្ងៃទី២៥ មេសា ២០១៧)
- http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ថតចម្លងនៅទី២៥ មេសា ២០១៧)
- siborann.blogspot.com/2011/09/blog-post_8065.html,Sep 14, 2011(ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)
- http://cambodia-financial-market.blogspot.com/2011/07/bond-sabay-securities-bond-share-sabay.htm l(ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)

- http://www.investopedia.com/terms/d/debenture.asp (ចូលទស្សនាថ្ងៃទី២៦ មេសា ២០១៧)
- http://www.investopedia.com/exam-guide/series-65/alternative-investments/derivative-securities.as (ចូលទស្សនានៅថ្ងៃទី ២៦ មេសា ២០១៧)
- http://www.investopedia.com/terms/i/issuer.asp#axzz1zYB0cza,Investropedia,Issuer (ទស្សនានៅថ្ងៃទី៨ មិថុនា២០១៧)
- http://www.phnompenhpost.com/business/platform-unify-online-trading-csx (ទស្សនាថ្ងៃទី ១០ មិថុនា ២០១៧)